លាង_ហាប់អាន

# ព្រះរាជសម្ភារៈ

## កវីរាជសតវត្ស៍ទី១៧



បណ្ណាគារ បន្ទាយស្រី

P3 2008
895.9323

# ព្រះរាជសម្ភារ

## កវីរាជសតវត្សទី១៧

ការស្រាវជ្រាវរបស់
លាង ហាប់អាន

HUN SEN LIBRARY
R.U.P.P.
0000019516

- បោះពុម្ពលើកទី១ ឆ្នាំ ១៩៦៤
ក្នុងទស្សនាវដ្ដីអក្សរសាស្ត្រខ្មែរ
- បោះពុម្ពលើកទី២ ឆ្នាំ ១៩៦៤
- បោះពុម្ពលើកទី៣ ឆ្នាំ ១៩៦៦

បោះពុម្ពសាជាថ្មីដោយ
លោក ស្រី ប៊ុនជន

ភ្នំពេញ,ថ្ងៃទី ១ វិច្ឆិកា ២០០៥

រក្សាសិទ្ធិ

# លំនាំដើម

សៀវភៅអ្នកនិពន្ធខ្មែរ ស្ដីអំពីព្រះរាជជីវប្រវត្តិ និងស្នាព្រះ-ហស្ដព្រះបាទរាជសម្ភារ សតវត្សទី១៧នេះ ជាកម្រងអត្ថបទដែលបានចុះផ្សាយលើកទី១ ក្នុងទស្សនាវដ្ដីអក្សរសាស្ត្រខ្មែរ ព្រមទាំងបោះពុម្ពផ្សាយលើកទី ២ ដោយបណ្ណាគារ ស៊ុន-ថៃ តាមរយៈមិត្ត ឌីក-គាម ។ ដោយហេតុថា កម្រងអត្ថបទបែបនេះ មានសារៈប្រយោជន៍ច្រើនចំ-ពោះកុលបុត្រអ្នកសិក្សា ហើយដោយឥឡូវនេះអស់ថែមទៅទៀតទើបខ្ញុំសំរេចប្រគល់សិទ្ធិបោះពុម្ពលើកទី ៣ ជូនបណ្ណាគារ សេង ងួន ហួត ចាត់ការផ្សាយ ។ ក្នុងការបោះពុម្ពលើកទី ៣ នេះ ខ្ញុំបានពិនិត្យនិងកែសម្រួលច្រើនបន្ដិ ។ ខ្ញុំសង្ឃឹមថា សៀវភៅបែបនេះនឹងកើតមានច្រើនដើម្បីប្រមូលនូវជីវប្រវត្តិនិងស្នាដៃសំខាន់ៗរបស់អ្នកនិពន្ធកវី ព្រមទាំងអ្នកប្រាជ្ញរបស់ជាតិយើងសំរាប់ជាគ្រឿងចេះដឹងរបស់សិស្សានុសិស្ស ។

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៦៦

លាង ហាប់ អាន

សាស្ត្រាចារ្យខាងភាសាខ្មែរ

# ព្រះរាជសម្ភារ

## កវីរាជក្នុងសតវត្សទី១៧[១] (១៦២៩-១៦៣០)[២]

### ១-រាជជីវប្រវត្តិ

### ក) តាមឯកសារបរទេស

១- តាមពង្សាវតាររបស់លោក "អាដេម៉ា ឡឺក្លែរ Adhémard Leclére" មានសេចក្តីថ្លែងថា ÷ ក្រោយព្រះទីវង្គតទៅនៃព្រះបាទ "ជ័យជេដ្ឋា" ឬ ព្រះជ័យចេស្តាទី ២ ក្នុង គ.ស ១៦២៨ (ក្នុង

---

(១) - Histoire du Cambodge, Adhémard-Leclère, 1914 page 340-342;

- Histoire du Cambodge, Mile Giteau, 1957, page 137;
- Le Cambodge, Louis Cheminais, 1960, page 50-51;
- Histoire du Cambodge A. Dauphin-Meunier,196, page 73;
- ព្រះរាជពង្សាវតារក្រុងកម្ពុជាធិបតី ខ្សែ ៤ បច្ចឹមសម័យទី ៣ (ច្បាប់សរសេរដៃនៅពុទ្ធសាសនបណ្ឌិត្យ លេខ ក ៣៥/៤ ពីទំព័រ ៣៧៣ តទៅ ។

(២) គឺជាឆ្នាំដែលទ្រង់គ្រងរាជសម្បត្តិ ។ តាមអត្ថបទលោក អាដេម៉ា ឡឺក្លែរ ទ្រង់គ្រងរាជ្យបាន ៩ ឆ្នាំ គឺពីឆ្នាំ ១៦៥១ ដល់ ១៦៥៩ (page 341) ។

ព្រះជន្មាយុបាន ៥២ ព្រះវស្សា, គ្រងរាជ្យបាន ១០ឆ្នាំ) ព្រះអនុជព្រះនាម ព្រះឧទ័យ ដែលមានព្រះជន្មាយុ ៤៨ វស្សាក៏បានទទួលកាន់កិច្ច-ការផែនដីមានព្រះឋានៈជា ព្រះឧបរាជនិងជាព្រះធម្មនាថយមរាជធំ។ ព្រះអង្គម្ចាស់អង្គនេះ ទទួលងារជាឧបរាជមកតាំងពី គ.ស ១៦១៨ម្លេះ ។ ទ្រង់កាន់ជាប់រហូតមកដល់ឆ្នាំ ១៦២៩ ។ ពេលនោះព្រះរាជបុត្រច្បងរបស់ព្រះបាទជ័យជេដ្ឋាជាព្រះរាម មានព្រះនាមថា ពញាសួរ (លោក **អាដេម៉ា-ឡឺគ្លែរ** ថាជាបុត្ររបស់អ្នកម្នាងសុខ?)(១) ក៏បានសឹកចាកសិក្ខាបទក្នុងព្រះជន្ម២៦វស្សា ។ ព្រះមហាឧបរាជមាក៏ប្រារព្ធផ្ទេរអំណាច អភិសេកក្មួយឡើងគ្រងរាជសម្បត្តិវិញ ។

ព្រះរាជាភិសេកប្រព្រឹត្តឡើងក្នុង គ.ស ១៦២៩ ។ ចៅពញាសួរទទួលបរមនាមថា ÷ "ព្រះបាទសម្តេច ស្តេចព្រះរាជឱង្ការព្រះស្រីធម្មោ រាជាធិរាជ រាមាធិបតី" ។ ប៉ុន្តែពង្សាវតារ កំណត់ព្រះនាមតែត្រឹម "ព្រះស្រីធម្មោរាជា" ឬ "ព្រះរាជសម្ភារ"(២) ។

ព្រះយុវក្សត្រ ទ្រង់ពុំសូវសព្វព្រះរាជហឫទ័យនឹងកិច្ចការនគរ ក៏ទ្រង់ផ្ទុកផ្តាក់អំណាច ថ្វាយព្រះអតីតរាជានុសិទ្ធមាជំនួស ដើម្បីបាន

---

(១) រាជពង្សាវតារខ្មែរថា ទ្រង់ព្រះនាមពញាតូ ។ បើតាមលោក អាដេម៉ា-ឡឺគ្លែរ ថា សួរ, សមនឹងមាតានាម សុខ ។

(២) តាមអត្ថបទពង្សាវតារ និងការស្រាវជ្រាវខេមរភាសាភាគច្រើន កំណត់ព្រះនាមថា "ព្រះបាទស្រីធម្មោរាជា" ។ ធម្មោរាជាមិនត្រូវបាលីទេ ។

ពេលដកព្រះអង្គទៅគង់នៅកោះឃ្លោក ក្នុងស្រុកខ្សាច់កណ្ដាល គិតតែនិពន្ធអក្សរសាស្ត្រ។ ព្រះរាជាអង្គនេះ ជាក្សត្រទ្រង់ធម៌ ជាបណ្ឌិតរាជ ។ ទ្រង់ទុកស្នាព្រហស្តជាអត្ថបទពាក្យពេចន៍ជាច្រើន ព្រមទាំងការងារខាងប្រវត្តិសាស្ត្រជាច្រើន ហើយដែលឥឡូវនៅសេសសល់តិចតួចពន់ពេក ។ ទ្រង់បានឱ្យផ្លាស់រាជស័ព្ទដែលព្រះរាជាមុនៗ បានកែប្រែដែរជាច្រើនដងនោះ ដោយសព្វព្រះរាជហឫទ័យឱ្យឆ្លើយឆ្លងនឹងព្រះអង្គថា "ព្រះរាជសម្ភារបារមីពិសេស" ហើយបើចំពោះព្រះអង្គមាកុំឱ្យថា "ព្រះភូវឌនាថ" ។

ឆ្នាំមួយនោះ ដោយការព្រមព្រៀងអំពី ព្រះបាទជ័យជេដ្ឋាបរមបិតា ធម្មោរាជា ទ្រង់ចាកសិក្ខាបទ ហើយកាន់កងទ័ពលើកទៅបម្រុងវាយយកខេត្ត "កូរ៉ាត"(នគររាជ) អំពីសៀម ។ ប៉ុន្តែការងារនេះពុំបានសម្រេច ។ ទ្រង់ដកទ័ពថយមកវិញ បានទាំងនាំយកនូវឈ្លើយជាច្រើនមកជាមួយផង ។

ពេលមួយទ្រង់គង់នៅអង្គរវត្ត ។ ព្រះមហាឧបរាជមា បាននាំរាជវង្សានុវង្សយាងទៅទទួល ។ ខណៈនោះព្រះយុវក្សត្រទ្រង់បានទតឃើញព្រះនាងក្សត្រី សុជាតិក្សត្រី(១) ដែលជាទេពីរបស់មា ជាហេតុបណ្ដាលឱ្យរលឹកឃើញរឿងដើម គឺថាព្រះក្សត្រីអង្គនេះជាគូគ្រងតាំងតែពីទ្រង់នៅជាកុមារម្ល៉េះ ។ កាលទ្រង់កំពុងគង់នៅក្នុងភេទបព្វជ្ជា

---

(១) ក្នុងឯកសារជាតិថា ព្រះនាមព្រះនាង "បុប្ផាវតី"

ស្ដេចមាបានរៀបការជាមួយទេពីទៅ ។ ពេលនោះសេចក្ដីរំជួលចិត្ត និង ស្នេហាក៏ដូចឡើងវិញ ។ ទ្រង់បានសន្យាជួបនឹងព្រះនាង, ក្សត្រីអង្គ នេះនៅជណ្ដើរមុខនាគ ហើយផ្លូវផ្គងក្នុងក្ដីស្នេហា ។ លុះត្រឡប់មក រាជធានីឧដុង្គវិញ ព្រះមហាឧបរាជទ្រង់ប្រឈួន ជាហេតុឱ្យអង្គការ ខ្ញែឃ្លាំមិនសូវតឹងរ៉ឹង ។ ព្រះយុវក្សត្រនិងព្រះនាងអង្គវតី បានទាក់ទង ស្នេហាបានញឹកញាប់ ។ ទាំងពីរព្រះអង្គប្រាថ្នាថា ព្រះឧបរាជនឹងទទួល ព្រះទីវង្គតពុំខាន, ប៉ុន្តែជាភ័ព្វអាក្រក់ ព្រះរោគរបស់ស្ដេចមាបានធូរ ស្រាលជាវិញ នាំឱ្យគូស្នេហាទាំងពីរអស់សង្ឃឹម ។ ទាំងទ្វេហាកើត ភ័យបារម្ភ ។ ព្រះនាងអង្គវតីក៏ភៀសរត់ចេញពីដំណាក់នៃព្រះឧបរាជ ស្វាមី ហើយយាងទៅគង់នៅក្នុងដំណាក់យុវក្សត្របណ្ដូលសង្សារ ។

ព្រឹត្តិការណ៍ក្នុងគ្រួសារនេះ បង្កើតនូវជម្លោះមួយយ៉ាងធំ ។ មនុស្សជាច្រើនគ្នា បានរិះគន់ព្រះមហាឧបរាជថា ÷ បានបំពារបំពាន រំលោភយកគូគ្រងរបស់ព្រះរជ្ជទាយាទ ។ អ្នកខ្លះ បែរជារិះគន់ព្រះ យុវក្សត្រថា ÷ ឡើងគ្រងរាជ្យហើយ ម្ដេចឡើយទៅបំពានយកទេពី ព្រះមហាឧបរាជមាទៅវិញ ។ ខ្លះទៀតកាន់ជើងព្រះនាងអង្គវតីថា ÷ ការដែលព្រះនាងត្រឡប់មកស្នេហា ចំពោះអតីតសង្សារដែលជាយុវ-ក្សត្រ ហើយបោះបង់ចោលស្វាមីចាស់ ដែលមានឋានៈជាមា និងជា រាជានុសិទ្ធតែប៉ុណ្ណោះ ជាការសមហេតុសមផលណាស់ ។ កំហឹងក៏ផ្ទុះ ឡើង។ ព្រះមហាកឧបរាជកេណ្ឌពលមួយកង ហើយព្រះរាជាក៏ប្រមូល

ទ័ពដែរ ។ ចម្បាំងគ្នាឯងក៏កើតឡើង ។ ប៉ុន្តែនៅក្នុងការពើបប្រទះដៃគ្នាជាដំបូង ពលរបស់ព្រះរាជាត្រូវបរាជ័យ ហើយមេទ័ពរបស់ទ្រង់ ៤ នាក់ ដែលជាជនជាតិចិនត្រូវស្លាប់ ។ ព្រះយុវក្សត្រនិងព្រះនាងអង្គវតីក៏ភៀសរត់ទៅខេត្តកញ្ជរ (ក្រចេះសព្វថ្ងៃ) ។ ប៉ុន្តែជាគ្រោះអាក្រក់មានកងទ័ពមួយពួកបានដេញទាន់ ហើយបានធ្វើគតទាំងពីរអង្គ ដោយគ្រាប់កាំភ្លើងទៅ ។

គិតទៅ ក្សត្រអង្គនេះបានគ្រងរាជ្យតែមួយឆ្នាំ ។ ទ្រង់សុគតក្នុងព្រះជន្ម ២៩ វស្សា[១] ។

## ២- តាមពង្សាវតាររបស់កញ្ញា "ម.ស្ទិតូ = M. Giteau"

មានសេចក្តីសង្ខេបថា ÷

រជ្ជកាលរាជភាពនៃចៅពញាតូ (១៦២៥-១៦៣១)[២] ព្រះបាទជ័យជេដ្ឋាបានអប់រំចៅពញាតូជារាជបុត្រយ៉ាងតឹងតែង រហូតបានជាព្រះអង្គម្ចាស់មានចំណេះជ្រៅជ្រះមួយព្រះអង្គ ។ ទ្រង់ប្រារព្ធអភិសេករាជបុត្រនេះនិងព្រះនាងក្សត្រីអង្គវតី ។ ប៉ុន្តែក្រោយព្រះទីវង្គតនៃព្រះបាទជ័យជេដ្ឋា ព្រះឧទ័យក៏រៀបអាពាហ៍ពិពាហ៍ ជាមួយយុវក្សត្រីទៅ ។ ពេលនោះយុវក្សត្រនៅក្នុងព្រះផ្នួសនៅឡើយ ។ ក្រោយ

---

(១) តាមអត្ថបទលោក Adhémard-Leclère page 342 ថា អត្ថបទខ្លះនិយាយថា ទ្រង់គ្រងរាជ្យបាន ៨ ឆ្នាំ ។ សុគតក្នុងព្រះជន្ម ៣៧ វស្សា ។

(២) តាមឆ្នាំនេះឃើញថា ខុសគ្នាឆ្ងាយពីពង្សាវតារដទៃៗទៀត ។

គ្រាលាចាកសិក្ខាបទ ព្រះអង្គម្ចាស់ក៏បានរាជាភិសេកជាស្ដេចផែនដី ។ ពេលមួយយុវក្សត្រជួបនឹងព្រះនាងអង្គវតីអតីតសង្សារ ក៏កើតស្នេហា ។ អង្គវតីក៏បោះបង់ចោលព្រះស្វាមី ហើយព្រះរាជានិងម្ចាស់ក្សត្រីនេះក៏នាំគ្នាភៀសរត់ ព្រះឧទ័យដេញតាមទាន់ ហើយក៏ប្រហារចោលទាំងពីរព្រះអង្គទៅ[១] ។

**៣-តាមស្នាដៃរបស់លោក "លួី-សឺមីណេ** =Louis Cheminais" មានសេចក្ដីបញ្ជាក់ថា ÷

ព្រះបាទជ័យជេដ្ឋា ទ្រង់ទុកនូវព្រះរាជបុត្រ ២ អង្គនៅពេលទ្រង់ចូលសុវណ្ណគតនាព្រះបរមរាជវាំងក្រុងឧដុង្គ ។ ទារុណភាពមួយក៏កើតឡើងនៅក្នុងគ្រួសារ ធ្វើឱ្យប្រទេសរំជួលហើយដល់នូវសង្គ្រាមគ្នាឯង ។ ពេលនោះយុវព្រះអង្គម្ចាស់ពញាតូ នៅបួសជាព្រះសង្ឃដើម្បីបន្តការសិក្សារបស់ទ្រង់ ។ ឯមហាឧបរាជ នាមព្រះឧទ័យជាបិតុលាកាន់តំណែងជារាជានុសិទ្ធ ។ មហាឧបរាជឆ្លៀតឱកាសល្អក៏រៀបការជាមួយយុវក្សត្រីអង្គវតីទុកជាទេពីទីពីរ ដែលព្រះរាជាព្រះរាមបានផ្សំផ្គុំជាស្រេចជាមួយនឹងរាជបុត្ររបស់ព្រះអង្គ ។ យុវក្សត្រទ្រង់យាងទៅអង្គរជាមួយនាម៉ឺនសព្វមុខមន្ត្រីក្នុងវាំង ដើម្បីទស្សនាបុរាណដ្ឋានក្រោយពីពេលសឹក ហើយឡើងគ្រងរាជ្យជាស្ដេចផែនដី ។ ក្នុងកិច្ចទស្សនានេះ ព្រះពញាតូបានជួបប្រទះនូវអតីតសង្សារ ដែលស្ដេចមា

---

(១) តាមដំណើររឿងនេះ ស្របគ្នានឹងអត្ថបទ "អាដេម៉ា-ឡឺក្លែរ" ។

បានបំពារបំពានយកទៅ ហើយទ្រង់ក៏បានសន្ទនាយ៉ាងស្ងាត់នៅទីលាន ខាងក្រៅអង្គរវត្ត ដោយបានស្បថស្បែគ្នា ក្នុងទឹកចិត្តស្នេហាប្រតិព័ទ្ធ យ៉ាងស្រងូតស្រងាត់ ។ ព្រះរាជាត្រឡប់មករាជធានីឧដុង្គវិញ ក៏នាំ អង្គវតីមកក្នុងដំណាក់ទ្រង់ ។ ការណ៍នេះបង្កើតជាចម្បាំងរវាងស្តេច មានិងក្មួយឡើង ។ ក្នុងការជួបប្រទះជាដំបូង កងទ័ពរបស់ព្រះរាជា បរាជ័យ មេទ័ពជនជាតិចិន ៤ នាក់ត្រូវស្លាប់ក្នុងសមរភូមិ ។ ព្រះរាជា ត្រូវតែភៀសខ្លួន ហើយរត់ទៅខេត្តកន្ថោ(១) (Can tho) ជាមួយគូ ស្នេហ៍ ។ ទ័ពឧបរាជដេញតាមទាន់ ។ គូសង្សារកំសត់ទាំងពីររូប ក៏ ត្រូវស្លាប់ដោយគ្រាប់កាំភ្លើង(២) ។

**៤- តាមសៀវភៅពង្សាវតារប្រទេសកម្ពុជា របស់លោក "អា. ដូហ្វាំង មើនីញេ** = A. Dauphin-Meunier" មានសេចក្តីបញ្ជាក់ថា ÷

រាជភាពក្នុងវាំង ព្រះអង្គម្ចាស់ឧទ័យ កាន់ងារជារាជានុសិទ្ធ (១៦២៨-១៦២៩) រហូតដល់ព្រះពញាតូ ជាព្រះរាជបុត្រច្បងរបស់ ព្រះបាទជ័យជេដ្ឋា ដែលនៅបួសជាសង្ឃ ទ្រង់បានជន្មាយុគ្រប់គ្រាន់នឹង ឡើងគង់ក្រោមស្វេតឆ័ត្រ ។

---

(១) គឺកញ្ជូរនេះឯង "ចារា សរសេរខុសទេ ។ កុញ្ចៈ ទេដឹង ?

(២) អត្ថបទនេះក៏មិនខុសពីរបស់លោក "អាដេម៉ា-ឡឺក្លែរ" ដែរ តែកន្លែងខ្លះពុំត្រឹមត្រូវ ដូចអត្ថបទមុនឡើយ ។

ពញាតូជាពុទ្ធសាសនិក ជាបណ្ឌិត មិនសូវសព្វព្រះទ័យនឹងការងារនគរទេ ។ ទ្រង់បានរកព្រះកាតព្វកិច្ចមួយ ក្នុងគោលបំណងវាយយកខេត្តនគររាជ អំពីសៀមមកវិញ ទើបប្រគល់កិច្ចការខាងអំណាចថ្វាយស្តេចមា ។ ជាអកុសលនៅពេលយាងទស្សនាអង្គរ ទ្រង់បានជួបនឹងទេពីមួយអង្គ ក្នុងបណ្តាទេពីទាំងឡាយរបស់ស្តេចមា គឺព្រះនាងអង្គវតី ដែលព្រះបិតាបានផ្សំផ្គុំហើយតាំងពីកាលទ្រង់នៅជាកុមារ ។ ទ្រង់ប្រារព្ធឱ្យព្រះនាងក្សត្រី វិលមកគង់នៅជាមួយក្នុងព្រះរាជតំណាក់ព្រះអង្គ ។ ព្រះឧទ័យបំបះប្រជាជន ឱ្យប្រហារកងរក្សាព្រះអង្គជាជនជាតិចិនរបស់ព្រះរាជា ហើយបំភ័យយុវក្សត្រនិងសង្សារ ឱ្យរត់រហូតដល់ទៅខេត្តកញ្ជរ ។ ព្រះឧទ័យដេញតាមទាន់ ហើយប្រហារដោយគ្រាប់កាំភ្លើងនូវគូសង្សារទាំងពីរនេះទៅ[១] ។

ខ) តាមឯកសារជាតិ[២]

មានសេចក្តីបញ្ជាក់ពីកាលបរិច្ឆេទឡើងគ្រងរាជ្យដូចតទៅ ÷

ព្រះពុទ្ធសករាជ ២១៧១ មហាសករាជ ១៥៤៩ ចុល្លសករាជ ៩៧៩[៣] ឆ្នាំថោះនព្វស័ក គ្រិស្តសករាជ ១៦២៧ ថ្ងៃ ០៥កើត ខែ

---

(១) អត្ថបទនេះប៉ែកអន្លើខ្លះ តែដូចគ្នាច្រើននឹងរបស់លោក Adhémard-Leclère

(២) តាមព្រះរាជពង្សាវតារក្រុងកម្ពុជាធិបតី ខ្សែ ៤ បច្ចឹមសម័យទី ៣ តម្កល់នៅ ពុទ្ធសាសនបណ្ឌិត្យ ច្បាប់សរសេរដៃ លេខ ក៥៣៤ ពីទំព័រ ៣៧៣ តទៅ ។

(៣) បើតាមឯកសារបរទេស ខុសឆ្នាំគ្នាដល់ទៅ ៩៧ ឆ្នាំ ។

កត្តិក ម៉ោង ៧ ព្រឹក ជាថ្ងៃមង្គលរឹក្សប្រពៃ ព្រះស្រីធម្មរាជា ជាព្រះរាជបុត្រច្បងនៃព្រះបាទជ័យជេដ្ឋា ព្រះជន្ម ២៦ ឆ្នាំ ស្តេចឡើងរាជាភិសេកសោយរាជសម្បត្តិតពីសម្តេចព្រះបិតុច្ឆា សម្តេចព្រះបរមរាជាមហាឧបរាជ ព្រមនឹងព្រះរាជគ្រូបុរោហិត ថ្វាយព្រះឧទកធារាភិសេក ។

ថ្ងៃក្រោយស្តេចចេញប្រទក្សិណព្រះនគរ ៣ ថ្ងៃ មុខក្រសួងឱ្យទៅសាងព្រះរាជវាំង[១] គង់នៅកោះឃ្លោករ ជ្រោយចង្វារក្នុងខេត្តភ្នំពេញ (ក្រោយមកជាខេត្តខ្សាច់កណ្តាលវិញ) ។

ព្រះស្រីធម្មរាជា ទ្រង់មានបញ្ញាឆ្លៀវឈ្លាស ចេះនូវព្រះត្រៃបិដកយ៉ាងជំនាញទាំងគតិធម៌ គតិលោក ទាំងព្រម ។ ទ្រង់ជ្រាបស្ទាត់នូវការតែងបញ្ហាកាព្យឃ្លោងនិងបាលី ។ ទ្រង់តែងច្បាប់ប្រាប់ប្រាមប្រដៅដូចជា ÷

- ច្បាប់ហៃសាធុនជន ឱ្យឈ្មោះថាច្បាប់ត្រីនេត្រ ។
- ច្បាប់ក្រម (សម្រាប់ប្រដៅមនុស្ស ឱ្យប្រព្រឹត្តដោយយុត្តិធម៌) ។

ព្រះរាជាទ្រង់សព្វព្រះទ័យ យាងទៅក្រសាលសាកសួរបញ្ហាបាលីនឹងព្រះសុគន្ធមានបុណ្យ (ងារជាព្រះសុគន្ធាធិបតីមហាសង្ឃរាជ) គង់ក្នុងអារាមមួយនៅក្រុងឧត្តុង្គជ័យ ។

---

(១) កាលមុននៅឧត្តរមានជ័យ

តាំងពីព្រះបាទសម្តេចព្រះស្រីធម្មរាជា ជាអម្ចាស់ទ្រង់សោយរាជ្យសម្បត្តិមក ព្រះពុទ្ធសាសនាថ្កើងរុងរឿងឡើង ។ បណ្តារាស្ត្របានសេចក្តីសុខក្សេមក្សាន្ត ។ លុះដល់ឆ្នាំមមីទោស័ក ទ្រង់ប្រារព្ធនឹងសេនាបតីមន្ត្រីទាំងពួងថា គួរលើកទ័ពទៅវាយស្រុកសៀម ពីព្រោះព្រះចៅក្រុងអយុធ្យាពុំញញើតខ្មែរ ពីកាលសម្តេចព្រះវររាជបិតាគង់ព្រះជន្មនៅ វាហ៊ានលើកព្យុហយាត្រាមកយុទ្ធនាការពីរដង ។ ទ្រង់ព្រះរាជបញ្ជាឱ្យកេណ្ឌរាស្ត្រខ្មែរខេត្តបាភ្នំ, រំដួល, ស្វាយទាប, ទ្រាំង, សំរោង-ទង, បាទី ចំនួន ៣ ម៉ឺននាក់, ដំរី ៥០ ក្បាល, សេះ ២០០ ក្បាល, ឱ្យកេណ្ឌរាស្ត្រ ខេត្តព្រះត្រពាំង, ក្រមួនស, ទ្រាំងត្រើយត្បូង, ពាម, បន្ទាយមាស, កំពត បញ្ចូលជាកងទ័ព ដាក់គយល្បាតរក្សាបង្ការក្រែងសៀមលើកទ័ពមកតាមជើងទឹក ។

នៅថ្ងៃ ១ រោច ខែ មិគសិរ ឆ្នាំមមីទោស័ក ទ្រង់ចាត់ ឧកញ៉ាក្រឡាហោមសួស, ឧកញ៉ាចក្រីមៅ និងឧកញ៉ាយោធាសង្គ្រាមប៉ុល ឱ្យលើកទ័ពតាមផ្លូវជើងគោក តម្រង់ទៅស្រុកមហានគរវត្ត ហើយលើកហួសទៅវាយស្រុកនគររាជសេមា ។ ទ័ពខ្មែរមានជ័យជំនះ ចាប់បានសៀមឈ្លើយ ស្បៀងអាហារ សាស្ត្រាវុធ ដំរី សេះច្រើន លើកទ័ពត្រឡប់មកក្រុងកម្ពុជាវិញ ។ ព្រះរាជាទ្រង់ខ្វាល់នឹងមេទ័ពទាំង ៣ ដែលលើកទ័ពទៅវាយស្រុកសៀមឈ្នះហើយ មិនបង្ហួសទៅវាយដល់ទីក្រុងយកជ័យជំនះទៀត ។ ទ្រង់ឱ្យនាំសៀមឈ្លើយទាំងនោះ ទៅ

ប្រគល់ឱ្យព្រះឥន្ទវិជ័យ ឱ្យនៅក្នុងខេត្តបរិបូណ៌ ។

ចំណែកពួកចិនបានដឹងថា ព្រះនគរកម្ពុជា ជាទីសុខសប្បាយ បរិបូណ៌ ក៏ចុះសំពៅមកនៅរកទទួលទានកាន់តែច្រើនឡើងៗ ។

ទ្រង់ព្រះមេត្តាប្រោសតាំងព្រះអង្គនន់ ជាព្រះរាជបុត្រច្បងនៃ សម្តេចព្រះបរមរាជាមហាឧបយោរាជ ត្រូវជាព្រះអនុជ ព្រះអយ្យកោ មួយនឹងព្រះអង្គ ជាស្តេចព្រះបទុមរាជា ។

ទ្រង់ឱ្យរើសចិន ៤ នាក់តាំងជាមន្ត្រី ជានាយត្រួតលើពួកចិន មានទីជា ÷

- ចុងតុក១
- ឡុកចុងអៀ១
- សាមចាន់ទៀវ១
- ចុងចិនតុក១ ។

ក្រោយនោះ សម្តេចព្រះបរមរាជាមហាឧបយោរាជ ទ្រង់ព្រះ អាពាធជាទម្ងន់ ។ ព្រះរាជាទ្រង់យាងទៅរក្សាព្រះរោគ សម្តេចព្រះ បិតុច្ឆា នៅព្រះបរមរាជវាំងឧដុង្គ ។ វេលានោះសម្តេចព្រះមហាឧប-យោរាជ ទ្រង់ត្រាស់បង្គាប់ព្រះម៉ែយួរវត្តីរាជទេពី ឱ្យរៀបភោជនាហារ ថ្វាយសម្តេចព្រះស្រីធម្មរាជាសោយរាល់ថ្ងៃ ។ ខណៈនោះព្រះស្រីធម្ម-រាជា ទ្រង់មានព្រះទ័យប្រតិព័ទ្ធនឹងព្រះម៉ែយួរវត្តី ជាព្រះរាជទេពី សម្តេចព្រះបិតុច្ឆា ត្រូវជាព្រះអនុជផ្សេងព្រះមាតា លបលាក់ប្រើទៅ

មក លុះទាល់តែសម្ដេចព្រះមហាឧបយោរាជសះជាព្រះរោគ ។

នៅខែចែត្រ ឆ្នាំមមែត្រីស័ក សម្ដេចព្រះមហាឧបយោរាជ ទ្រង់យាងទៅថ្វាយព្រះពុទ្ធបដិមានៅព្រះមហានគរវត្ត ។ សម្ដេចព្រះស្រីធម្មរាជា ក៏ទូលថាតាមហែទៅផង ។ ព្រះបាទសម្ដេចព្រះស្រី-ធម្មរាជា កាលស្ដេចឡើងទតប្រាសាទ ទ្រង់ឃើញព្រះម៉ែយូរវត្តី រឹតតែមានព្រះទ័យស្នេហាខ្លាំងឡើង ប្រើព្រះនេត្ររកគ្នាទៅមក រួចស្ដេចយាងចុះមកមុនសម្ដេចព្រះបិតុច្ឆា ។ លុះព្រលប់ ស្ដេចតែងព្រះអង្គក្លែងជាចិន ទ្រង់ឈរបន្លំនឹងពួកចិនលេងភ្លេង ។ ដល់ព្រលប់ងងឹតនោះ សម្ដេចព្រះមហាឧបយោរាជ ទ្រង់យាងចុះមកអំពីប្រាសាទជាក្រោយ. សម្ដេចព្រះស្រីធម្មរាជា ទ្រង់លបចាប់ហត្ថព្រះម៉ែយូរវត្តី ដោយព្រះទ័យស្នេហា មត់សញ្ញាទៅវិញទៅមក ។

ព្រះបាទសម្ដេចព្រះស្រីធម្មរាជាស្ដេចយាងមកវិញ ទ្រង់ព្រះបរិវិតក្កនឹកដល់ព្រះម៉ែយូរវត្តីយ៉ាងខ្លាំង ភ្លេចទាំងស្រង់សោយ រួចទ្រង់តែងព្រះរាជលិខិតជាសេចក្ដីលោមស្រែច ស្ដេចចាត់ពួកស្រីចាស់ទុំនាំទៅថ្វាយព្រះម៉ែយូរវត្តី[១] ។

ព្រះម៉ែយូរវត្តីទតចប់ រឹងមានព្រះទ័យស្នេហាយ៉ាងខ្លាំង ព្រោះព្រះវររាជបិតាទ្រង់បានផ្សំទុកតាំងពីកុមារមកម្ល៉េះ ។

លុះដល់ខែ ជេស្ឋ ឆ្នាំមមែត្រីស័ក ព្រះម៉ែយូរវត្តី ក្រាបថ្វាយ

---

(១) សូមមើលនៅផ្នែកស្នាព្រះហស្ថ ។

បង្គំទូលព្រះស្វាមីដោយឧបាយថា ទៅលេងបឹងផ្គំមួយយប់ ពីរយប់ ។ ទើបក្សត្រីទ្រង់នាំពួកស្រីចាស់ទុំដែលចូលគំនិត ចុះគង់ព្រះទីនាំងនាវា ចេញអំពីឧដុង្គ ឱ្យចែវបង្ហួសរហូតទៅដល់ព្រះរាជវាំងកោះឃ្លោក ខេត្តខ្សាច់កណ្ដាល ដែលសន្មតហៅថាកោះឧញ៉ាតី ។ សម្ដេចព្រះស្រីធម្ម-រាជាទ្រង់ជ្រាប ស្ដេចចេញទទួលព្រះម៉ែឃ្មូរវត្តិដោយព្រះទ័យស្នេហា ទ្រង់ឃាត់ទុក ៣ យប់ ។ មន្ត្រីដែលមិនបានចូលគំនិត ក៏ត្រឡប់មកក្រាបបង្គំទូលសម្ដេចព្រះមហាឧបយោរាជតាមរឿងគ្រប់ប្រការ ។ ទ្រង់ក្រោធយ៉ាងខ្លាំង ទើបចាត់ទាហ៊ានបារាំងនិងមន្ត្រីសម្រាប់ព្រះអង្គជាកងទ័ពទឹក មានពល ៥០០ ទូកចម្បាំង ៣០០ ឱ្យលើកទៅធ្វើសង្គ្រាមនឹងសម្ដេចព្រះភគ្គនិយោ [១] ។ ព្រះស្រីធម្មរាជាក៏ទ្រង់ព្រះរាជបញ្ជានូវសេនាបតីមន្ត្រីសម្រាប់ឯក ឱ្យប្រមូលទាហ៊ានចិនសម្រាប់ព្រះអង្គមកជួបជុំ ។ ទ័ពប្រទះគ្នានៅព្រែកព្នៅក៏បាញ់កាំភ្លើងទៅវិញទៅមក ។ កងទ័ពខាងសម្ដេចព្រះមហាឧបយោរាជមានកាំភ្លើងច្រើន បាញ់ទៅត្រូវពលសម្រាប់ឯកស្លាប់ច្រើនណាស់ ។ ពួកទាហានចិនខ្មែរទ្រាំពុំបានក៏បាក់ថយចែវទូកទៅវិញ ។ ខាងសម្ដេចព្រះមហាឧបយោរាជមានជ័យជំនះ លើកដេញរៀងទៅដល់កោះឃ្លោក ឡើងគោកបាក់ទ័ពរត់ខ្ចាត់ខ្ចាយ ។ ព្រះស្រីធម្មរាជាទ្រង់គ្រឿងរាជ្យសម្រាប់យុទ្ធនា នាំយោធារក្សាព្រះអង្គចេញទទួល ទ្រង់ចាត់មេទ័ពចិនទាំង ៤ រូប ចូល

(១) ភាគនេយ្យា ទើបជាបាលីត្រឹមត្រូវដែលប្រែថា ក្មួយ ។

ប្រកាប់ប្រចាក់នឹងពួកបារាំងខ្មែរ ។ មេទ័ពចិនក៏ត្រូវទាហ៊ានបារាំងបាញ់ស្លាប់ បាក់ទ័ពបរាជ័យ ។ ព្រះរាជាឃើញថាសឹកលើសកម្លាំង ក៏នាំមន្ត្រីរត់ចេញចោលព្រះរាជវាំង ។ ខាងសម្តេចព្រះឧបយោរាជដេញតាម ។ ព្រះរាជាស្តេចបែកទ័ពរត់នឹងរាជភេរីដោះយកជីវិត ចុះគង់ព្រះទីនាំងនាវាឆ្លងទៅត្រើយឯកើត ។ ពួកបារាំង[១] ខ្មែរក៏ដេញតាមទៅដល់ខេត្តស្រីសឈរ ។ ទីនោះគ្មានព្រៃ ។ ព្រះបាទសម្តេចព្រះស្រីធម្មរាជារត់ទៅតែមួយព្រះអង្គ ។ លុះរាជសត្រូវដេញទៅជិតទ្រង់ព្រះដម្រិះថា មុខជារត់ពុំរួចនឹងគេ ស្តេចទតឃើញរបោះព្រៃត្នោតច្រើន ក៏ឡើងពួនបំបាំងព្រះអង្គលើចុងត្នោត ទ្រង់យកព្រះសែងស្នៀត កាត់កំពូលត្នោតចារឹកជាពាក្យកាព្យ[២] ។ ទាហ៊ានបារាំង ដើររកមើលពុំសល់ដើមត្នោត បានឃើញស្តេចនៅលើចុងត្នោត ហើយហៅគ្នាចោមលើកកាំភ្លើងឡើងនឹងធ្វើគត ។ ទ្រង់ទតឃើញដូច្នោះ ស្តេចរាព្រះហស្ថមានព្រះតម្រាស់ដោយព្រះសូរសៀងយ៉ាងខ្លាំងថា ÷

**"បារាំងអប្បលក្ខណ៍ វាដេញបាញ់អ្នក ព្រះរាជសម្ភារ**
**ឡើងលើចុងត្នោត ពុំកោតចេស្តា អ្នកលើកហត្ថា**
**រារាំងឃាត់ទុក" ។**

ក្រោយការចារពាក្យឃ្លោងឰដ៏កំពូលត្នោតចប់ ទ្រង់ទម្លាក់ចុះ

---

(១) សៀវភៅកម្ពុជាវតារចែងថាពួក ព័រទុយហ្គេ = Portuguais ។

(២) សូមមើលខាងផ្នែកស្នាព្រះហស្ថ ។

ឱ្យពួកបារាំង ហើយមានព្រះរាជតម្រាស់ផ្ដាំថា បើអ្នកឯងរាល់គ្នាសម្លាប់អញហើយ អាណិតយកសេចក្ដីនេះ ទៅក្រាបបង្គំទូលថ្វាយសម្ដេចព្រះបិតុច្ឆាឱ្យអញផង ។

នៅថ្ងៃ ១០ កើត ខែ ភទ្របទ ឆ្នាំមមែត្រីស័ក វេលារសៀលត្រជាក់ ទាហ៊ានបារាំងព័រទុយហ្គេសបាញ់ទៅត្រូវព្រះអង្គក្ស័យព្រះជនធ្លាក់ពីចុងត្នោតមកដល់ដី ។

ព្រះរាជសម្ភារទ្រង់គង់ក្នុងរាជសម្បត្តិបាន ៥ ឆ្នាំ ព្រះជន្ម ៣០ ឆ្នាំ[១] ស្ដេចទីវង្គត ព្រះរាជបុត្រគ្មាន ។ មន្ត្រីខាងព្រះឧបយោរាជប្រជុំកងទ័ព អញ្ជើញព្រះសពដាក់ក្នុងព្រះស្ថាន រួចដង្ហែត្រឡប់មកព្រះរាជវាំងកោះឃ្លោក ចាប់ព្រះម៉ែយួរដាក់ក្ដី រួចបញ្ជូនព្រះរាជទ្រព្យចុះទូកមកព្រះបរមរាជវាំងឧដុង្គឮជ័យ ។ សម្ដេចព្រះឧបយោរាជ ទ្រង់ទតឃើញ មានព្រះបន្ទូលថា គួរស្ដាយណាស់ ដ្បិតរកក្រស័តឯណាមានបញ្ញាដូចគ្មាន តែទុកឱ្យនៅទៅនឹងខូចប្រវេណី ដ្បិតពុំតម្រង់ដោយទសពិធរាជធម៌ ជាព្រះរាជកិត្យរបស់ព្រះមហាក្រស័ត ។ ទ្រង់ត្រាស់ឱ្យធ្វើគតព្រះម៉ែយួរវត្តិតាមច្បាប់ ។

## គ- សេចក្ដីបញ្ជាក់បន្ថែមអំពីរាជជីវប្រវត្តិនេះ

តាមព្រះរាជពង្សាវតារសរសេរដៃនៅពុទ្ធសាសនបណ្ឌិត្យ ខ្មែរ

---

(១) តាមសេចក្ដីនេះ ឃើញថាមានត្រូវខ្លះនិងខុសខ្លះ បើប្រៀបនិងច្បាប់ដែលបរទេសសរសេរ ។

៤ បញ្ជាក់ពី ÷

១- ព្រះរាជសម្ភារ ព្រះអង្គជារាជបុត្រព្រះបាទជ័យជេដ្ឋា និងអ្នកម្នាងសុក ដែលជាបុត្រីឧកញ៉ាវាំងកិម ។ ទ្រង់ប្រសូតនៅថ្ងៃ ២ កើត ខែពិសាខ ចុល្លសករាជ ៩៦៤[១] ។ ព្រះវររាជបិតាដាក់ព្រះនាមថាព្រះអង្គតូ, ក្រោយមកជាព្រះស្រីធម្មរាជា ( ទំព័រ ៣៤៦) ។

២- ព្រះអង្គវត្តីជារាជបុត្រីព្រះបាទជ័យជេដ្ឋា និងអ្នកម្នាងទង ដែលជាបុត្រីសម្ដេចចៅពញាហ៊ុយ ។ ព្រះនាងប្រសូតនៅថ្ងៃអាទិត្យ ១៥ កើត ខែ ផល្គុ ឆ្នាំកុរត្រីស័ក ច.ស ៩៧៣ ។ ព្រះក្សត្រីអង្គនេះជាកនិដ្ឋារួមមាតាជាមួយព្រះអង្គទងរាជា ព្រះពញានូវ ដែលប្រសូតនៅថ្ងៃព្រហស្បតិ៍ ៨ កើត ខែបុស្ស ឆ្នាំវកសំរឹទ្ធិស័ក ច.ស ៩៧០ ( ទំព័រ ៣៤៧) ។

៣- បព្វជ្ជារបស់ព្រះរាជសម្ភារ ព្រះរាជសម្ភារចូលបព្វជ្ជាក្នុងព្រះជន្ម ២២ ឆ្នាំ នៅវត្តព្រះសុគន្ធមានបុណ្យ នាថ្ងៃ ១៤ កើត ខែអាសាឍ ឆ្នាំកុរ បញ្ចស័ក ( ទំព័រ ៣៦៥) ។

៤- ការទាក់ទងរបស់ព្រះបាទឧទ័យ និងព្រះនាងអង្គវត្តី កាលព្រះបាទសម្ដេចព្រះជ័យជេដ្ឋាព្រះជន្មបាន ៤១ ឆ្នាំ គឺក្នុងខែកត្តិក ឆ្នាំឆ្លូវសប្តស័ក[២] ទ្រង់អាពាធ ។ សម្ដេចព្រះបរមរាជា មហាឧយោរាជ

(១) តាមសករាជនេះពុំទាន់ប្រាកដនៅឡើយទេ ព្រោះធៀងនឹងឯកសារបរទេស ឆ្លើយពុំត្រូវគ្នាសោះ ។

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.

ស្តេចចូលទៅព្យាបាលរក្សារោគ នៃសម្តេចព្រះរាមក្នុងព្រះបរមរាជ-វាំងរាល់ថ្ងៃ ទ្រង់មានព្រះទ័យប្រតិព័ទ្ធនឹងអ្នកអង្គវត្តី ជាព្រះរាជបុត្រីព្រះជ័យជេដ្ឋា ត្រូវជាព្រះភគ្គនិយោបង្កើត ។ អ្នកអង្គវត្តីក៏ទ្រង់ព្រមព្រះទ័យផង មិនគិតអាល័យព្រះស្រីធម្មរាជា ដែលសម្តេចព្រះវររាជបិតាទ្រង់ផ្សំផ្គុំព្រះរាជទានជាគូ សេនាបតីមន្ត្រីទាំងពួង ក៏ដឹងរាល់គ្នា (ទំព័រ៣៦៩) ។

## ២- ស្នាព្រះហស្តរាជសម្ភារ (៣)

ស្នាព្រះហស្តនេះ នៅក្នុងលក្ខណៈស្រាវជ្រាវផ្ទាល់របស់ខ្ញុំ តាមឯកសារដូចមានរាយខាងដើម តាមការប្រៀបធៀបឧត្តមគតិ អត្ថរូបសំនួនវោហារនៃអត្ថបទ ។ ហេតុដូច្នេះពុំអាចសន្និដ្ឋានថាពិតទាំងស្រុងនៅឡើយទេ ។

អត្ថបទខ្លះ ខ្ញុំបំបែកពីគ្នាតាមផ្នែកដើម្បីឱ្យឈ្មោះដោយឡែក ហើយខ្លះដែលនៅក្នុងបុច្ឆនសញ្ញា គឺឋិតក្នុងការពិចារណាថែមទៀត ។

១- ច្បាប់រាជនីតិ?

២- ច្បាប់ព្រះរាជសម្ភារ.

---

(២) បានព្រះជន្ម ១៥ ឆ្នាំ ។

(៣) ស្នាព្រះហស្តទាំងនេះមានឯកសារត្រឹមត្រូវ តាមព្រះរាជពង្សាវតារ ដកលំនៅពុទ្ធ-សាសនបណ្ឌិត្យ ព្រមទាំងចុះផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយា និងសាស្ត្រានៅក្រុមពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការនៅភ្នំពេញ ។

៣- លិខិតផ្ញើទៅថ្វាយព្រះម៉ែឃ្លូរវត្តី,

៤- ពាក្យកាព្យចារឰដ៏កំពូលត្មោត មុនពេលសុគតដោយទាហ៊ានបារាំងបាញ់ ។

៥- កំណាព្យសរសើរហេមន្តមាស,

៦ - កំណាព្យ "កន្លង់មាសមង្គលថ្លៃ"

៧- កំណាព្យ "ព្រលឹងមាសអើយ"

៨- ច្បាប់ក្រម,

៩- ច្បាប់ហៃសាធុជន ឬ ច្បាប់ត្រីនេត្រ ។

តទៅនេះ យើងនឹងលើកយកស្នាព្រះហស្ថនិមួយ ៗ មកដកស្រង់ធ្វើអត្ថាធិប្បាយបញ្ជាក់នូវលក្ខណៈអត្ថបទ អត្ថរូប និងអត្ថរស (តាមមតិផ្ទាល់) ដើម្បីទុកជាការពិចារណា និងជាឯកសារសរុបទំហំគុណបំណាច់ ក្នុងការឧបត្ថម្ភដំកើងអក្សរសាស្ត្រជាតិ របស់ព្រះមហាក្សត្រអង្គនេះ ។

# លក្ខណៈពិសេសខ្លះនៃស្នាព្រះហស្ថ

## ១- ច្បាប់រាជនីតិ

ច្បាប់នេះ ពុទ្ធសាសនបណ្ឌិត្យនៃក្រសួងធម្មការ បានចម្លងចេញពីសាស្ត្រាស្លឹករឹតបោះពុម្ពផ្សាយលើកទី១ ក្នុងកាល ព.ស ២៤៨៤ គ.ស. ១៩៤១ ។

យើងមានការស្តាយពន់ពេក ព្រោះពុំមានការបញ្ជាក់នូវព្រះនាមអ្នកនិពន្ធ និងសករាជនៃការតែងឱ្យច្បាស់ ។ ប៉ុន្តែយើងអាចសន្និដ្ឋានតាមការយល់ឃើញថា ច្បាប់នេះប្រាកដជាព្រះរាជសម្ភារ ទ្រង់ប្រារព្ធនិពន្ធក្នុងពេលបំពេញសមណភេទសិក្សាបាលី ច្បាប់ក្បួន អក្សរសាស្ត្រជាតិ ។ គ្រាន់តែសេចក្តីផ្តើមជាបឋម ក៏អាចបញ្ជាក់ថាអ្នកនិពន្ធមានចំណេះខាងភាសាបាលី និងអក្សរសាស្ត្រជាតិច្បាស់លាស់ណាស់ដូចមានសេចក្តីដកស្រង់តទៅនេះ ÷

**រាជនីតិសត្ថំ វញ្ញោ ទិដ្ឋធម្មត្ថសាធនំ វុច្ចតេ ពុទ្ធិវុឌ្ឍត្ថំ បររដ្ឋវិមទ្ទនេ ។**

រីគម្ពីររាជនីតិសាស្ត្រ ដ៏ទ្រង់នូវប្រយោជន៍ **ពុទ្ធិវុឌ្ឍនត្ថំ** មានចម្រើនប្រាជ្ញាជាប្រយោជន៍ **បររដ្ឋវិមទ្ទនេ** ក្នុងកិរិយាញាំញីបង់នូវខេត្ត

ដែននៃសត្រូវ ទិដ្ឋធម្មត្ថសាធនំ ឱ្យសម្រេចប្រយោជន៍ក្នុងទិដ្ឋៈ **រញ្ញោ** នៃព្រះមហាក្សត្រិយ៍ព្រះរាជា **មយា** គឺអញខ្ញុំ **វុច្ចតេ** ពោលឥឡូវនេះ។ **ជានេយ្យ ភាសនេ ពុទ្ធី** អង្គណាចង់ដឹងអ្នកមានប្រាជ្ញា ឥតប្រាជ្ញា ក្នុងវេលានិយាយ និងចង់ដឹងអ្នកមានសីលវត្ត និងមិនមានសីលវត្ត ក្នុងវេលានៅជាមួយគ្នា និងចង់ដឹងអ្នកស្អាតមិនស្អាត ក្នុងវេលាធ្វើការទាំងពួង និងចង់ដឹងមនុស្សល្អអាក្រក់ក្នុងកាលវេលាមានភ័យមកដល់... ។

ឯសេចក្តី និងអត្ថន័យនៃច្បាប់ទាំងមូល បើបំព្រួញនៅត្រឹមលក្ខណៈអប់រំ ទូន្មាន ចំពោះអ្នកគ្រប់គ្រងរដ្ឋ (ពិសេស គឺព្រះមហាក្សត្រិយ៍) ដូចមានតទៅ ÷

## មនុស្សចំពូកផ្សេងៗដែលព្រះរាជាត្រូវលះបង់ ឬជ្រើសរើសយក

### ១- មនុស្ស ៨ ចំពូកដែលព្រះរាជាត្រូវលះបង់ចោល

១- មនុស្សខ្ជិលច្រអូស

២- មនុស្សមានចិត្តអាក្រក់

៣- មនុស្សល្ងង់ខ្លៅ

៤- មនុស្សមានមារយាទអាក្រក់

៥- មនុស្សធ្វើការរមែងខូច

៦- មនុស្សបិទបាំងទោសខ្លួន

៧- មនុស្សមិនសន្តោសគេ

៨- មនុស្សមិនក្លៀវក្លា ។

### ២- មនុស្ស ៧ ចំពូកដែលព្រះរាជាមិនគួរចិញ្ចឹម ឱ្យធ្វើជាអ្នកសម្រេចការឡើយ

១- មនុស្សសំដីអាក្រក់.

២- មនុស្សកាច់កិនគេ,

៣- មនុស្សលោភ,

៤- មនុស្សមិនហាត់ក្នុងធម្មសាស្ត្រ និងរាជនីតិ,

៥- មនុស្សឃើញតែប្រយោជន៍ខ្លួន មិនឃើញប្រយោជន៍អ្នកដទៃ មានម្ចាស់ផែនដីជាដើម,

៦- មនុស្សរមឹលគុណម្ចាស់,

៧- មនុស្សនិយាយកុហក ។

## ៣- ទោស ៣ ប្រការមានដល់ព្រះមហាក្សត្រ ដែលតាំងមនុស្សវង្វេងទុកជាទីប្រឹក្សា

១- គ្មានឥស្សរិយយស និងបរិវារយស,

២- វិនាសប្រយោជន៍

៣- ស្លាប់ហើយនឹងទៅកើតក្នុងនរក ។

## ៤- គុណ ៣ ប្រការមានដល់ព្រះរាជា ដែលតាំងអាមាត្រមានប្រាជ្ញាជាទីប្រឹក្សា

១- មានឥស្សរិយយស និងបរិវារយស

២- មានសម្បត្តិដ៏ឧត្តម ដោយយុត្តិធម៌

៣- ស្លាប់ហើយ នឹងទៅកើតក្នុងសុគតិសួគ៌ ។

## ៥- ព្រះរាជាគួរតម្កល់មនុស្សដូចតទៅ ឱ្យជាធំក្នុងទីពិភាក្សាផ្សេងៗ

១-មនុស្សដែលមានត្រកូល

២- មនុស្សមានសីលគុណ

៣- មនុស្សមានពាក្យសត្យ

៤- មនុស្សមិនប្រព្រឹត្តទៅក្នុងអគតិទាំង៤

៥- មនុស្សមានប្រាជ្ញាពិចារណាល្អ

៦- មនុស្សពោលពាក្យពិរោះ

៧- មនុស្សឆ្លៀវឆ្លាសក្នុងរាជសាស្ត្រ និងធម្មសាស្ត្រ ។

## ៦-ព្រះរាជាគួរតាំងមនុស្សប្រកបដោយគុណ៥ ជាចៅហ្វាយឃ្លាំង

១- មនុស្សមានជាតិត្រកូលជាអ្នកទៀងត្រង់.

២- មនុស្សបានហាត់ព្យាយាមរក្សាព្រះរាជទ្រព្យឱ្យល្អ

៣- មនុស្សស្គាល់ត្រកូលកែវទាំងពួង.

៤- មនុស្សធ្វើការស្អាតមិនភ្លាំងភ្លាត់.

៥- មនុស្សធ្វើចិត្តឱ្យទៀងត្រង់( មិនឆរាស្ត្រ មិនបំបាត់ហ្លួង)

## ៧-ព្រះរាជាតាំងនាយទ្វារគួររើសមនុស្ស៦ចំពូក

១- អ្នកស្គាល់មនុស្សចាស់ថ្មី.

២- មនុស្សមានស្មារតី.

៣- មនុស្សមានរូបកាយសមរម្យ.

៤- មនុស្សអត់ធន់នូវលំបាក.

៥- មនុស្សមានការងារដ៏ស្អាត

៦- មនុស្សឈ្លាសក្នុងការសាកសួរដ៏ល្អិត ។

## ៨- ព្រះរាជាតាំងរាជទូតគួររើសមនុស្ស ប្រកបដោយគុណ ៦ យ៉ាង

១- មនុស្សមានប្រាជ្ញា,

២- មនុស្សចេះសំដី,

៣- មនុស្សអ្នកក្លៀវក្លា

៤- មនុស្សចេះកំណត់ចិត្តអ្នកដទៃបាន.

៥- មនុស្សមានគំនិតល្អិត

៦- មនុស្សដឹងពាក្យដែលគួរនឹងស្តីបាន.

## ៩- ព្រះរាជាតាំងមនុស្សជាអាល័ក្ខ គួររើសអ្នកប្រកបដោយហេតុ ៦

១- មនុស្សដែលកំណត់ពាក្យពោលតែម្តងក៏ចាំបាន.

២- មនុស្សសរសេររហ័ស.

៣- មនុស្សមានថ្វីដៃល្អ.

៤- មនុស្សមានប្រាជ្ញាវាងវៃ

៥- មនុស្សចេះសំដី.

៦- មនុស្សឈ្លាសក្នុងលក្ខណៈអក្សរ និងលេខ

## ១០- ព្រះរាជាតាំងសេនាបតី

## គួររើសមនុស្សប្រកបដោយអង្គ ៩

១-មនុស្សមានប្រាជ្ញាក្នុងគ្រឿងញាំញីបរបក្ស

២- មនុស្សដឹងទីជ័យភូមិ

៣- មនុស្សនាកាលយ៉ាប់ចុន មិនចោលគ្នា

៤- មនុស្សដឹងកងពល ពាហនៈលំបាក

៥- មនុស្សប្រកបដោយព្យាយាម

៦- មនុស្សក្លៀវក្លា

៧- មនុស្សអត់ធន់សុខទុក្ខនឹងម្ចាស់

៨- អត់ធន់សុខទុក្ខនឹងពួកខ្លួន

៩- មនុស្សចេះគម្ពីសេនាង្គព្យូហៈ ។

## ១១- ព្រះរាជានឹងតាំងជាពិសេសគួររើស មនុស្សប្រកបដោយគុណ ៤

១- មន៉ុស្សធ្លាប់ជាពួកពិសេសត ៗមកពីជីតា

២- មនុស្សឈ្លាសក្នុងការដណ្តាំស្ល

៣- មនុស្សចេះដណ្តាំស្លល្មមប្រមាណ

៤- មនុស្សនៅជាពួកពិសេសដរាបមក ។

## ១២- ព្រះរាជានឹងតាំងពេទ្យត្រូវរើស មនុស្សប្រកបដោយគុណ ៥

១- មនុស្សចេះគម្ពីពេទ្យ ចេះថ្នាំដែលឱ្យចម្រើនអាយុ

២- មនុស្សឈ្លាសក្នុងការរក្សារោគ

៣- មនុស្សចេះតាក់តែងសារពើថ្នាំ

៤- មនុស្សមានរូបរាងដ៏ល្អ

៥- មនុស្សប្រកបដោយសីលាចារគុណដ៏ប្រសើរ

## ១៣- ព្រះរាជានឹងតាំងសេវកាត្រូវរើស មនុស្សប្រកបដោយគុណ ៧

១- មនុស្សដឹងអធ្យាស្រ័យម្ចាស់.

២- មនុស្សស្អាត

៣- មនុស្សឈ្លាសវៃ

៤- មនុស្សប្រព្រឹត្តធម៌

៥- មនុស្សចេះគម្ពីជាច្រើន

៦- មនុស្សលោភតិច

៧- មនុស្សមិនភ្លេចស្មារតី

## ១៤- ព្រះរាជានឹងតាំងបុរោហិតត្រូវរើស មនុស្សប្រកបដោយគុណ ៣

១- មនុស្សចេះតម្រាសាស្ត្រភេទធំតូច

២- មនុស្សឈ្លាសក្នុងការបូជាយញ្ញ

៣- តាំងមេត្តាចិត្តចំពោះព្រះរាជាឱ្យចម្រើនព្រះជន្មវែង ។

## ១៥- ព្រះរាជានឹងតាំងក្រុមវាំងត្រូវរើស

### មនុស្សប្រកបដោយអង្គ៧

១- មនុស្សចេះរក្សាខ្លួន

២- មនុស្សស្លូតត្រង់

៣- មនុស្សឈ្លាសភាសាផ្សេងៗ

៤- មនុស្សត្រេកអរក្នុងធម៌

៥- មនុស្សចេះសិល្បសាស្ត្រផ្សេងៗ

៦- មនុស្សប្រកបដោយត្រកូល និងសីលគុណ

៧- មនុស្សកោតខ្លាចម្ចាស់

## ១៦- ព្រះរាជានឹងតាំងមន្ត្រីត្រូវរើស មនុស្សប្រកបដោយអង្គ៤

១- មនុស្សមានវិចារណបញ្ញា

២- មនុស្សម្ចាស់មានវវល់ មិនធុញទ្រាន់

៣- មនុស្សក្លៀវក្លា

៤- មនុស្សមានសេចក្តីគិតអានច្រើន

## ១៧- ព្រះរាជាប្រសើរប្រកបដោយអង្គ៦

១- មានសម្ពន្ធមិត្រអាចញាំញីបរបក្ស ហើយវាងវៃក្នុងការរណរង្គ កាច់បង់នូវកលនៃបរបក្ស ហើយជាទីពឹងនៃប្រជាជន

២- ទ្រង់រំលឹកនូវការងារទាំងពួង

៣- ចេះធ្វើបរបក្សឱ្យបាក់បបដោយយុត្តិធម៌

៤- មានព្រះហឫទ័យក្លៀវក្លា និងព្យាយាមច្រើន

៥- មានព្រះស្មារតីខ្ជាប់ខ្ជួន

៦- ទ្រង់ព្រះប្រាជ្ញាជ្រាបការវិនាស និងចម្រើន ។

## ១៨- អ្នកមានគុណ ៨ ទុកស្មើនឹង ព្រះមហាក្សត្រទ្រង់ទសពិធរាជធម៌

១- ព្រះឥន្ទ្រ

២- ព្រះចន្ទ្រ

៣- ព្រះអាទិត្យ

៤- ព្រះពាយុទេវតា

៥- ព្រះយមរាជ,

៦- មហាសមុទ្រ

៧- ភូមទេវតា

៨- វស្សវលាហកទេវតា ។

## ១៩- អ្នកប្រកបដោយអង្គ ៨ ទើបធ្វើមន្ត្រីបាន

១- បានស្ដាប់មកច្រើន,

២- មានសីលគុណ,

៣- មានព្យាយាមច្រើន,

៤- ធ្វើរាជការរួចឆាប់,

៥- មានកម្លាំងច្រើន,

៦- លោភតិច,

៧- មានរូបជាទីស្រឡាញ់,

៨- ក្លៀវក្លា ។

សរុបសេចក្ដីសង្ខេបប៉ុណ្ណេះយើងឃើញថា ទោះបីមានលក្ខណៈអប់រំ ផ្ដួលទៅតាមសាសនា (ពិសេសព្រហ្មញ្ញ និងពុទ្ធសាសនាខ្លះក៏ដោយ) ក៏ច្បាប់នេះរាប់បញ្ចូលជានីតិសាស្ត្រ ប្រកបដោយរបៀបរៀបរយ ក្នុងនយោបាយគ្រប់គ្រងប្រទេស របស់រាជាធិបតេយ្យខ្មែរ តាំងពីសម័យបុរាណមកទល់បច្ចុប្បន្នកាលនេះ ។ គឺជាច្បាប់រំលេចនូវចំណេះទូទៅមួយប្រកបដោយចិត្តសាស្ត្ររបស់ មនុស្សយ៉ាងបរិបូរណ៍ ។

## ២- ច្បាប់ព្រះរាជសម្ភារ[១]

ជាច្បាប់ឧបទេសប្រដៅទូន្មាន ប្រកបដោយពាក្យពេចន៍ដែលមានឧត្ដមគតិយ៉ាងជ្រៅ ។ ឃ្លាប្រយោគនិងវគ្គខ្លះ ក្លាយទៅជាសុភាសិត មានខ្លឹមសារនិងគតិទូន្មាន ដែលអ្នកសិក្សានិងខេមរជនភាគខ្លះចាំរត់មាត់សូត្រប្រដៅគ្នាបានយ៉ាងធូរ ។

ឯលក្ខណៈពិសេសនៃការអប់រំ គឺឋិតនៅលើ ÷

- គុណវិបត្តិទូទៅរបស់បុគ្គលមួយរូប១,
- គុណវិបត្តិពិសេសរបស់បុគ្គល,

---

(១) ច្បាប់នេះមិត្ត លី ធាមតេង បានចម្លងចាកសាស្ត្រាដើម បោះពុម្ពផ្សាយរួមនឹងច្បាប់កេរ្តិ៍កាល ក្នុងគ.ស ១៩៥៧ ។ មិត្រ តេង ឱ្យឈ្មោះច្បាប់រាជនីតិដែរ ។

- បញ្ហាទាក់ទងរវាងបុគ្គល និងអ្នកដទៃ (ក្នុងសង្គមជាតិ ឬបរទេស) ។

### ក) គុណវិបត្តិទូទៅរបស់បុគ្គល

គុណវិបត្តិនេះ ឋិតនៅលើត្រៃទ្វាររបស់បុគ្គល ដែលមានផ្លូវកាយ វាចា និងចិត្ត ។

### ១- ផ្លូវកាយ

កាយដែលប្រកបដោយភាពខ្ជិលច្រអូស, ទ្រមក់, ខ្សោយស្គីកពុំរហ័សរហួន, ពុំទន់ភ្លន់, ខ្វះសកម្មភាពក្នុងដំណើរជីវិតផ្ទាល់ខ្លួន ឬទាក់ទងនឹងអ្នកដទៃក្នុងគ្រួសារក្តី សង្គមជាតិទូទៅក្តី ។ ព្រះករីរាជទ្រង់ទូន្មានថា ÷

"ខ្លែងហើរដ្បិតខ្យល់ នាយថ្មើងដ្បិតពល រក្សាឱ្យសុខ
ទ្រព្យគង់ដ្បិតស្រី ចេះសំចៃទុក ផ្ទះធំស្រណុក
ដ្បិតភរិយាជា ។
បាត់យសដ្បិតខ្ជិល បាត់ញាតិទានសីល ដ្បិតសេពសុរា
ប្រមាថបាត់បុណ្យ ខឹងបាត់ប្រាជ្ញា លេញលេងដៀលថា
បាត់ឥរិយាគាប់ ។
ប្រាជ្ញពុំស្មើពុត បម្រើលំឱត ពុំស្មើក្តីគាប់
មានគុណពុំស្មើ អ្នកមានបុណ្យភ័ព្វ ស្វែងរៀនរកច្បាប់
ពុំស្មើចិត្តជា ។

សក្តិពុំស្មើយស អ្នកមានរបស់ ពុំស្មើស័ក្កា
សូវបង់ធនធាន កុំខុសអាជ្ញា សូវមានរោគា
កុំឱ្យមើលងាយ" ។

## ២- ផ្លូវវាចា និងចិត្ត

អុជអាល ជេរប្រមាថ ភូតភរ វាចាអាក្រក់ ទ្រគោះ អសច្ចៈ ពុំទៀងទាត់ ព្រហើន ឈ្លានពាន។ ចិត្តបាបអាក្រក់ ឥតខ្មាសឥតអៀន ទុច្ចរិត អកុសល អសទ្ធា អសប្បុរស ប្រកបដោយអវិជ្ជា លោភៈ ទោសៈ ក្រោធៈ មោហៈ អប្បឥតបញ្ញា ឥតស្មារតី កំសាកពុំអង់អាច កាចសាហាវ យងឃ្នង ទោមស្សឥតស្រាក ច្រណែនប្រច័ណ្ឌ ឈ្នានីស សងសឹក ។ល។ ដែលជាមូលហេតុនាំឱ្យព្រះកវីរាជាទូន្មានថា ÷

-"កុំជឿងដោយខ្យល់ កុំឱនពាក្យពល កុំខ្វល់ដោយស្រី
កុំកាន់ពិសយង់ គប់នឹងអស្ត្រី សមណៈជនជី
កុំឱ្យក្តីត្រូវ ។
កុំនៅញ៉ាំងឈ្លោះ កុំស្តាប់អសុរស កុំស្តាប់អាស្រូវ

....................

-"ផ្តែមពីរប្រការ ចំណោរទៅដាល កុំអាលឱ្យឆី
ផ្តែមមួយពាក្យពោល តែងរាលរកក្តី ផ្តែមមួយពាក្យស្រី
ស្រដីមាយា ។
ពាក្យត្រូវវែងរឹង ស្រាវែងស្រវឹង ពុំដែលពិសា

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY

ពាក្យពិតវែងស្លែង ពុំពីរោះថា បណ្ដាំមេបា
វែងថាពុំគាប់" ។

.....................

-"ល្អិតកញ្ចពីពាក្យ សាកសួររកសាច់ សន្ដានព្រេងព្រឹទ្ធិ
រកពិះកលអ្វី សុចរិតទុច្ចរិត ហើយហោងគួរគិត
ឱ្យដឹងខ្ពស់ទាប ។
ដូចខ្នាក់បាំងស្បែក មួយដូចទំពែក ចង់សុំប្រេងលាប
ដូចថ្លង់ស្ដាប់ច្រៀង ទះដៃព្រាប១ ដូចខ្វិនអាបឡាប
ចង់ចងក្បិនរត់" ។

.........................

-"ពាក្យខុសកុំស្ដាប់ ក្ដីខុសកុំត្រាប់ អ្នកកាចកុំផ្ចិត
ល្ងង់កុំស្រដី ខ្សត់កុំទុកចិត្ត ពាលោកុំផ្ចិត
ជាមិត្តមេត្រី" ។

.........................

-"ពិដោរផ្កាបី ពិដោរមេត្រី សួរសីលាចារ្យ
ពិដោរបរិសុទ្ធ កុសលសម្ភារ ពិដោរនេះដាល
ដល់សួគ៌ពុំស្បើយ ។
ពិសាផ្លែប្រាំ ពិសារសធម្ម ពិសាសត្យា
ពិសាសីលទាន ទ្រើសទ្រង់ករុណា ពិសារស

វាចាចេញមធូរ" ។

## ខ) គុណវិបត្តិពិសេសរបស់បុគ្គល

គុណវិបត្តនេះ ឋិតនៅលើការខ្វែងចិត្តគំនិត ឬវិបត្តិទំនាស់របស់ ÷

- បុគ្គលនឹងខ្លួនឯង (ខ្លួនឯងល្អ អាក្រក់ មានបាន ក្រលំបាក ទុក្ខសុខ ចម្រើន វិនាស ច្រឡំ)

- បុគ្គលនឹងអ្នកដទៃ (ក្នុងគ្រួសារឬក្រៅគ្រួសារក្តី ដូចជាខ្លួនជាអ្នកក្រជាមួយគេជាអ្នកមាន អ្នកល្ងង់និងចេះ ខ្ញុំនិងម្ចាស់ មនុស្សត្រឹមត្រូវ និងមនុស្សអាក្រក់ ។ល។)

- ខ្លៅរែងស្អប់ចេះ ខ្សត់ឥតចំណេះ ស្អប់អ្នកមានទ្រព្យ
ស្រីស្រាលប្រច័ណ្ឌ រែងស្អប់ខ្ញុំគាប់ ពាលពិតឥតច្បាប់
រែងស្អប់ប្រដៅ ។
ចង់បុណ្យបានបាប ចចើងចង់លាភ រែងបាត់ធន់ទៅ
មានះបាត់មិត្ត ឥតអ្នកជាផៅ ក្រេវក្រោធឃោរឃៅ
រមែងបាត់អង្គ" ។
-"ខ្លៅរែងស្អប់ប្រាជ្ញ នាអ្នកខ្លបខ្លាច រែងធ្វើជាហ៊ាន
ខ្សត់ខ្សោយស្ទុតទ្រុឌ រែងធ្វើជាមាន អ្នកឥតសណ្តាន
រែងគេមើលងាយ" ។

..........................

"រៀនក្តីគួរគិត ចាស់ឥតប្រព្រឹត្ត នៅប្រែច្រឡំ
អ្នកជាជាកាច តូចប្រែជាធំ ពង្សពូជឧត្តម
ច្រឡំជារាស្ត្រ ។
ឃើញសេះជាលា យល់ក្ងានជាទា ពពាយជាទាស
សំណជាប្រាក់ ស្ពាន់ឆ្លាក់ជាមាស បង្គួយជាជាស
កប្បាសជាគ ។
ហេតុនេះគួរគិត គួររិះរកហិត ដឹងរសគន្ធរ
ពិដោរអសុដោរ ពិសារសាទរ ហិតហើយគប្បីប-
រិកោក្តាក្តាត់" ។
"ផ្ទះភ្លើងមានបី អំពើពុតស្រី ខឹងឥតប្រមាណ
កូនកាចចចេស ពុំដោយទូន្មាន ខ្ញុំកាចជៀសប្រាណ
ពុំឱ្យម្ចាស់ប្រើ ។
ហោរាប្រើគួរ ភមូប្រើមូល ស្ទង់ទឹកប្រើស្មើ
បន្ទាត់ប្រើត្រង់ ពលផ្ទង់គប្បីប្រើ ពុំហើយគប្បីធ្វើ
កុំលែងគប្បីភ្វា ។
ក្តីកោតមានបី កោតមួយពួកស្រី ស្រដីមាយា
កោតមួយពាក្យពិស អាស្រូវជេរថា កោតមួយពាក្យពា-
លាលោភទុជិន" ។

**គ) បញ្ហាទាក់ទងរវាងបុគ្គលនិងអ្នកដទៃ**

អប់រំស្មារតីឱ្យស្គាល់មិត្ត ស្គាល់សត្រូវ ស្គាល់ខុសត្រូវ ចម្រើនវិទាស ក្នុងការរស់នៅរាល់ថ្ងៃ តាមការប្រកបជីវភាពក្តី ការទាក់ទងញាតិក្តី ។

-"កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្រ្កម៏ កុំទុកចិត្តអភិប្រាយ
ប្រើផ្គុំវែងខ្ពស់ រំពឹងឱ្យឆ្ងាយ ស្តាប់ពាក្យបរិយាយ
បណ្តាំមេជី" ។

"កុំដើរពានស្ទុន កុំកាត់ច្រកផ្លូវ កុំធ្វើស្រែស្រូវ
នៅផ្លូវដំរី" ...............

"អត់ឱនឥតទោស ធ្វើចិត្តសន្តោស បង្កើតជាទ្រព្យ
មេត្រីជាញាតិ រក្សាដល់ស្លាប់ ជឿសក្តីពុំគាប់
ជាគន្ធពិដោរ ។

ទឹកបាក់ទៅទាប បុណ្យបាត់ដ្បិតបាប លាភបាក់ដ្បិតឃោរ
ទឹកថ្លាដ្បិតរលក ពុំយល់ស្រមោល ទោសកើតដ្បិតពោល
ល្មមមាត់ឈ្លានពាន" ។

......................

"បណ្ឌិបមេបា អំបូរលោកថា ទូកតាមកំពង់
សំពៅតាមខ្យល់ ចង្កូតតម្រង់ មេលឹមតែងត្រង់
ត្រីវិស័យជាមុខ ។

ដូចចិត្តប្តីជា ដូចមានភរិយា នៅផ្ទះស្រណុក

ដូចកូនទទួល យកពាក្យឪពុក ដូចខ្ញុំឱ្យមុខ
អម្ចាស់ប្រើហៅ ។
បណ្ឌិបមេបា អំបូរលោកថា ព្រេងព្រឹទ្ធប្រដៅ
ទើងឆីប្រើរក ទើងស្វែងប្រើទៅ ទើងស្នេហ៍ប្រើ
ហៅមិត្តមកជាមិត្ត" ។

..................

"ធ្វើស្រែមើលស្មៅ សន្តានមើលផៅ បម្រើមើលពុត
ទោះដឹងពុតជា ពុំចេះពុត្បុត ដឹងចិត្តបរិសុទ្ធ
ពុំចេះឥរិយា ។
ទេពីមើលក្រិត្យ ក្សត្រាមើលឫទ្ធិ ទាហានមើលចេស្តា
ជាងមើលអំពើ អំពីហត្ថា ទោះយកភរិយា
មើលនាលំនៅ " ។

...................

"អ្នកបួសឥតក្រឹត្យ ចាស់ឥតប្រព្រឹត្ត ខ្សត់ច្រើនប្រមាទ
កិរិយាផុយផាយ ចាយវាយឥតខ្មាត ពលពាលសុទ្ធសាធ
ប្រដៅក្របាន" ។

.....................

សង្ខេប ច្បាប់ព្រះរាជសម្ភារ ប្រដៅទូន្មានមនុស្សគ្រប់វណ្ណៈ ដើម្បីឱ្យពិចារណាកែតម្រង់ចិត្តគំនិត ប្រាជ្ញា ស្មារតីធ្វើខ្លួនឱ្យទៅជាជន

ប្រសើរប្រកបដោយកាយ វាចាចិត្ត សុចរិតត្រឹមត្រង់ អង់អាចក្លាហាន សមឋានៈជាពលរដ្ឋភ្ញាក់រលឹកស្គាល់ខុសត្រូវ ល្អ អាក្រក់ គុណទោសនេះឯង ។ ច្បាប់នេះអប់រំសង្កត់ទៅលើជីវភាពសាមញ្ញជន ច្រើនជាងការលើកតម្កើងអភិជន ទើបយើងរាប់បញ្ចូលច្បាប់នេះ ជាស្នាដៃប្រជាប្រិយមួយក្នុងសតវត្សទី ១៧ ។ គឺជាច្បាប់ដែលប្រជាជនរាប់ពាន់រក្សា ចម្លង ទន្ទេញ ត្រិះរិះពិចារណាមករហូតទល់សព្វថ្ងៃនេះ រាប់យូរសតវត្សមកដែរហើយ ។ ព្រះករីរាជអង្គនេះ ពិតមែនតែទ្រង់ជាក្សត្រផែនដី ប៉ុន្តែព្រោះហេតុតែព្រះអង្គបានទ្រង់ព្រះផ្នួស មានជីវភាពរស់នៅផ្ទាល់នឹងព្រះសង្ឃ និងរាស្ត្រអ្នកស្រុក ទើបព្រះអង្គទ្រង់ស្គាល់ជីវភាពសាមញ្ញជនទាំងឡាយយ៉ាងច្បាស់ ដែលជាបុព្វហេតុឱ្យការរៀបរាប់ពាក្យទូន្មាន ចុចត្រូវចំណុចការរស់នៅ និងការទាក់ទងរវាងនាម៉ឺនរាស្ត្រ ព្រះសង្ឃ ឧបាសក ឧបាសិកា ចៅហ្វាយនិងខ្ញុំបានត្រឹមត្រូវច្រើនតាមសម័យកាលនិងទំនៀមទម្លាប់អ្នកប្រទេសមួយផ្នែកធំ ។

# ស្នាព្រះហស្ថព្រះរាជសម្ភារ

## ៣-លិខិតផ្ញើទៅថ្វាយព្រះម៉ែឃួរវត្តី(១)

"មិត្តមេស្នេហ៍ស្នង  គូសាងនឹងបង  កាលកអវិជ្ជា
តែងត្រេចរង្កាត់  ក្នុងវដ្តភពភារ  ឆ្លាស់ឆ្លងប្រវាល
គម្ភីរជលស័យ ។
អន្ទោលតាមបង  រួមសុខទុក្ខផង  ជាអចិន្ត្រៃយ៍
កាលកប្បខ័ណ្ឌ  ទាំងកំបាំងឆ្ងាយក្រៃ លន្លោចនៅក្នុង
សង្សារភពចក្រ ។
ជាតិនេះបងបាន  ជួបកែវកល្យាណ  កាយកបនរលក្ខណ៍
ស្មានជាអញបង  បានគ្រងរួមរ័ក្ស  ប្រតិព័ទ្ធនឹងអ្នក
ប្រក្រតីលង់ទៅ ។
ហេតុតែមានកម្ម  ពីព្រេងនាយនាំ  ឱ្យបងនិងពៅ
និរាសចាកចិរ  ជាពីរលំនៅ  ពុំបានរ័ក្សពៅ

---

(១) លិខិតនេះចម្លងចេញពីព្រះរាជពង្សាវតារក្រុងកម្ពុជាធិបតី ទំព័រ ៣៨៦-៣៨៧ ។ មាននៅក្នុងច្បាប់ដើមសរសេរនឹងក្រាំងខ្មៅ ជាព្រះរាជទ្រព្យរបស់សម្ដេចមាលិកា ។ ចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំ១៩៣៨ លេខ ៨ ទំព័រ ១០៣ តទៅ ។

ដូចក្តីប្រាថ្នា ។

សូមទានអម្រិ- ន្ទ្រាទិព្វចក្ខិ- ន្ទ្រីយ៍ទ្រង់ករុណា
សហស្សនេត្រនៃ នៅត្រៃចក្រពាឡ៍ ព្រះមកជួយជា
ទិសទិព្វញ្ញាណ ។

ទាំងទេពទិសទស ទូទាំងសោឡស មហាព្រហ្មមាន
រិទ្ធិអំណាច អង់អាចអភិញ្ញាណ សោតសឹងសោយឈាន
និរនេសទុក្ខា ។

សូមបងបានមូល មាសមិត្តបណ្តូល បណ្តាច់ស្នេហា
កុំឱ្យបងប្រាស និរាសច្នេះណា ប្អូនអើយបងផ្សា
ទ្រូងក្តៅសៅហ្មង ។

សូមសព្វៗជាតិ កុំឱ្យបងឃ្លាត ពីប្អូនស្នេហ៍ស្នង
ឱ្យបងបានជួប នឹងស្ងួនទួនល្អង កុំឱ្យបងរង
តែទុក្ខខ្លោចផ្សា ។

អញ្ជូខ្ញុំឧទ្ទិស សម្មាពុទ្ធស្ស ជាម្ចុងលោកា
ជាតិជាប្រធាន ទិព្វញ្ញាណថ្លៃថ្លា តែងជួយឱ្យប្រា-
កដកាលប្រណិធាន ។

សូមប្អូនបានជា បាទបរិចាគា អរិយពោធិញ្ញាណ
ស្រង់សត្វដាក់ដល់ ត្រើយថ្កល់និព្វាន លះលោកលែងឋាន
អបាយទុក្ខា ។

ស្រណោះប្អូនស្ងួន ទើបមូលជាខ្លួន ខ្ទឹមសង្សារសាច់
រួមរសមេត្រី ឥតបីមានដាច់ រិះរួតសម្រេច
សមរសស្នេហា ។

បងចាំនោះនៅ នាបងបានចៅ ហេមន្តមាសា
រហើយរហត់ កាន់កត់រងា ព្រះពាយវាំតា
ពាសពីឧត្តរ ។

ប្អូនអើយបងធ្យាន យល់បុណ្យបុរាណ ហើយទើបបងបរ-
បូណ៌បទបងបាន សេពសាន្តសាទរ នឹងព្រះប្អូនវរ
មិត្រមាសកល្យាណ ។

ទោះគន់គិតទៅ នាបងបានចៅ មិនគប្បីបាន
ហេតុបុណ្យបារមី ពិតពីបុរាណ ទើបប្អូនរួមឋាន
មូលមួយនឹងបង ។

យល់បុណ្យបងច្បាស់ បារមីក្រៃក្រាស់ បានប្អូនស្ងួនគ្រង
លុះលើគំនិត លើចិត្តបំណង មកមូលរួមរង
រាជរម្យស្នេហ៍ស្នាល ។

ប្អូនអើយសុរិយ៍ សួស្តីសូមរស្មី ឆ្លុះភ្លឺកណ្តាល
វេហាស៍មណ្ឌល សួស្តីសល់សម្ភារ ពិសេសពិសាល
ឯអាកាសនាយ ។

រីបងនិងចៅ មូលមេត្រីនៅ មណ្ឌលទីអាយ

ភ្លឺផ្លេកធរណី រស្មីព្រោងព្រាយ រួមរក្សាសាយ
កម្ពុជធានី ។
មួយព្រះឥន្ទ្រា មាននាងសុជាតា ជាឆ្នើមទេពី
សោយរាជវង្សរុង ចមចុងគិរី ជាឯកអគ្គឥ-
សូរសព្វទេវា ។
ឥឡូវនួនល្អង កើតកាលនេះម្តង ជាជេដ្ឋជាយា
រួមគ្រងរាជរម្យ សួស្តីសមសោភា បរិបូណ៌ភាមា
គឺរូបនារី ។
ប្អូនជាតិជាថ្លើម សាច់សួតដង្ហើម និងបងពិតពី
បុរាណនាយណា ទើបគ្រានាឥ- ឡូវលុះប្អូនស្រី
ដល់តូចចិន្តា ។
ប្អូនអើយបងច្បាន នាបងបានភាណ បានស្និទ្ធស្នេហា
មូលមិត្តមេត្រី បេតីជាអា- ចិណ្ណចិត្តមមា
មមៃនឹងមាស ។
ឱយើងលង់ឆ្ងាយ លុះដល់កាលនាយ កំព្រាហៅប្រាស
ចង់ឱ្យស្នេហ៍ស្និទ្ធ ផ្តេកផ្តិតសេយ្យាសន៍ នឹងមេមិត្តមាស
អស់កាលនាយនោះ ។
ឱ្យបងនិងស្ងួន ប្អូនទៅនែបខ្លួន កុំឱ្យបងបោះ
កុំឱ្យបងប្រាស ប្អូនមាសចេញស្មោះ ឱ្យរួមកួចកោះ

មេត្រីអាល័យ ។

បើបានដូចចិត្ត បំណងគំនិត មួលមួយហឬទ័យ
ទាំងនេះហៅបុណ្យ ពីមុនក្រាស់ក្រៃ ទើបបានមួលមៃ
ត្រឹមត្រូវអភិភាស"[១] ។

ទឹកដមនៃលិខិតនេះ ធ្វើឱ្យសេចក្តីស្នេហាប្រតិព័ទ្ធ ព្រមទាំងអនុស្សាវរីយ៍តាំងពីកុមារភាព និងការចាប់បណ្តាំរបស់ព្រះនាងម៉ែយូរវត្តិក្តី របស់ព្រះរាជសម្ភារក្តី ពុះពោរជាខ្លាំង ហើយហាក់ដូចជាដូចនូវកំហឹងចំពោះព្រះបិតុច្ឆា ដែលបានបំពារបំពាន បណ្តាំរបស់ព្រះវររាជបិតា (គឺព្រះរៀមរបស់ព្រះឧទ័យ) ។ កម្លាំងនៃរសរបស់លិខិតនេះហើយ ដែលធ្វើឱ្យព្រះម៉ែយូរវត្តី ប្តេជ្ញាលែងខ្លាចស្លាប់ ចាកចេញពីព្រះតំណាក់ស្វាមី យាងមករួមសុខទុក្ខជាមួយព្រះអតីតសង្សារ ។

តាមរយៈវោហារនៃព្រះរាជលិខិតនេះ យើងអាចវិនិច្ឆ័យនូវវិបត្តិទំនាស់រវាងក្សត្រទាំងពីរ ដែលឈ្លោះប្រកែកគ្នាពីរឿងព្រះនាងអង្គវត្តី ថាតើកំហុសមាននៅលើរូបអង្គក្សត្រណា?.. តើទំហំនៃសេចក្តីស្នេហារបស់លោកីយ៍ មានឥទ្ធិពលប៉ុនណា?

## ៥- ពាក្យភាព្យចារនឹងកំពូលគ្នោតមុនពេលទ្រង់សុគតដោយការបាញ់នៃទាហានបារាំង

"សាធុសម្ចាយ កុំបីរាយមាយ នឹងក្តីកាមា
តែឱ្យវង្វេង ក្នុងវដ្តសង្សារ ស្លាប់ទៅកាលណា

បានសោយតែទុក្ខ ។

ហេតុតែក្សត្រី នាំឱ្យអប្រិយ៍ ដូចត្រីក្នុងភក់
បើបុរសផង ចង់ឆ្លងនរក កុំធ្វើវីវក់
ដូចអញច្នេះណា ។
ពីព្រោះកាមេ ឥឡូវទាល់តែ ក្សិណក្ស័យមរណា
សូវស្លាប់ទៅគាប់ ឱ្យជាប់ធម្មា សូមអស់ទេវា
ជួយជាទិព្វញ្ញាណ ។
ទើបព្រះភូមិ- ន្ទ្រាធិបតិន ទ្រង់អធិដ្ឋាន
ពីនេះទៅមុខ ខ្ញុំសូមឱ្យបាន ជាព្រះពុទ្ធញ្ញាណ
នាំសត្វទាំងឡាយ ។
ឱ្យអ្នកទាំងពួង ជាទាហ៊ានលួង នាំយកទៅថ្វាយ
ព្រះបិតុច្ឆា ទ្រង់ជ្រាបអធិប្បាយ កុំទ្រង់រាយមាយ
នឹងក្ដីកាមេ ។(១)

បណ្ដាំចុងក្រោយបន្តិចប៉ុណ្ណេះ មិនគ្រាន់តែមានប្រយោជន៍សំរាប់លុបលាងនូវទោសកំហុសរបស់ទ្រង់ ក្នុងការរំលោភបំពារបំពានធមិកាមេប៉ុណ្ណោះទេ ។ វិសេសជាងនេះ ស្នាព្រះហស្ដនេះជាការប្រៀនប្រដៅព្រះបាទឧទ័យជាព្រះបិតុច្ឆា ដែលប្រព្រឹត្តអំពើមិនគប្បី ដែលពុំគោរពតាមពាក្យសន្យាផ្ដុកផ្ដាក់ផ្ដាំផ្ញើ របស់ព្រះបាទជ័យជេដ្ឋាដែលផ្សំ

(១) កំណាព្យនេះស្រង់ពីព្រះរាជពង្សាវតារ ទំព័រ ៣៩១-៣៩២ ។

ផ្ទុំជាស្រេចតាំងពីព្រះកុមារនូវព្រះយុវក្សត្រទាំងពីរនេះ ។ ម្យ៉ាងទៀត ពាក្យបណ្តាំប៉ុណ្ណេះ ក៏បញ្ជាក់ថាទោសនៃកាមតណ្ហានិងការបំពានធមិកាមេ ជាបាបកម្មមួយគួរអនុជនខ្លាចហើយកុំសង្វាតឱ្យសោះ ។ តម្លៃនៃកំណាព្យចុងក្រោយនេះអាចឱ្យយើងសន្និដ្ឋានថា ព្រះរាជសម្ភារទ្រង់ពិតជាបណ្ឌិតប្រាកដមែន ដោយហេតុថា ទ្រង់ស្គាល់នូវទោសកំហុសរបស់ទ្រង់ ហ៊ានសំដែងកំហុសដល់សាធារណជនឥតលាក់លៀម ហើយស៊ូស្លាប់នឹងអំពើអាក្រក់របស់ខ្លួនយ៉ាងក្លាហាន ។ ការស្លាប់ដោយដៃរបស់បរទេសបែបនេះ បង្ហាញនូវទោសកំហុសធ្ងន់ណាស់ របស់ព្រះឧទ័យស្តេចមា ។

## ៥-កំណាព្យសរសើរលោចន្តមាស[១]

ព្រះនិពន្ធរាជ ទ្រង់បានប្រារព្ធនូវស្នាព្រះហស្តនេះឡើង ក៏ក្នុងគោលបំណងថ្លែងនូវទុក្ខសោកខាងផ្លូវចិត្ត ចំពោះការនិរាសព្រាត់ប្រាសអំពីគូស្នេហា ដែលស្តេចមាទ្រង់បានពាំនាំយកទៅធ្វើជាទេពី ។ តាមរយៈកំណាព្យនេះ ព្រះរាជសម្ភារទ្រង់បានគូសវាស នូវទេសភាពពេលរសៀល ប្រកបដោយវាយោត្រជាក់និងតន្ត្រីយ៍ធម្មជាតិលាយឡំដោយសម្លេងខ្សៀវខ្សារនៃបក្សាបក្សី ។ ទ្រង់នាំយកនូវទិដ្ឋភាពព្រៃព្រឹក្សានទី មច្ឆានិងទីវាលធំធេងមកលាតត្រដាង ផ្សំប្រមុំជាមួយនឹងទឹកហ-

---

(១) កំណាព្យនេះជាអត្ថបទលិខិតផ្ញើទៅព្រះនាងអង្គវត្តី តែខ្ញុំចែកដាច់ដោយឡែកអំពីមុន ។ ស្រង់ពីកម្ពុជសុរិយាលេខ ៨ ឆ្នាំ១៩៣៩ ទំព័រ ១០៧ តទៅ ។

ឬទ័យនឹករលឹកដល់ព្រះនាងអង្គវត្តី ក្សត្រីបណ្ដូលជីវិត ដែលទ្រង់នឹកគិតពុំភ្លេចតាមព្រះរាជបណ្ដាំ ដែលព្រះវររាជបិតាផ្ញើផ្ដាំមកតាំងពីព្រះកុមារ ។ កំណាព្យនោះមានលំនាំដូចតទៅ ÷

## បទព្រហ្មគតិ

"ដំណែងដំណើរនា សរសើរគ្រាហេមន្តមាស
ត្រសៀកឯអាកាស សែងសាយណ្ហេទេរទៅ ។
ស្រណោះបក្សាករ ឯអម្ពរឆ្វៀងឆ្វាត់ស្លៅ
សំកុកសំកាំងនៅ សូងសូរស៊ានស័ព្ទយាសយំ ។
ខ្លះហើរប្រកៀងគូ ទំទៀងនៅទ្រង់ទ្រាយសម
ខ្លះសសិតស្លាបទំ ខ្លះហើរហួសផ្ដេកផ្ដោះទៅ ។
ខ្លះរេរកចំណី ដោយនាទីគង្គាជ្រៅ
ខ្លះឆ្មៀងឆាបសំដៅ ចាប់ចុកចឹកចង្វាស៊ី ។
គន់គួរស្រណោះសល់ ស្រណោះកលពួកបក្សី
សងសូរស័ព្ទសំដី រឿយៗរែកភាសាសត្វ ។
ស្រណោះឯគង្គា វែងរងថ្លាស្រុតស្រកក្ដាត់
មច្ឆារេរាថ្វាត់ហែល ហែបហាបន្ទៀកលេង ។
មើលព្រៃនាដងស្ទឹង ម្លប់ត្រឈើងលូតលាស់ឯង
ខ្យល់បក់ទន់ទន្ទេង លំទោនទងលតាដោយ ។
ស្រណោះបុប្ផាករ រៀបកេសរីករុះរាយ

គន្ធាត្រឡប់ដោយ　　វាតាផ្សព្វផ្សាយគន្ធរ ។
កន្លង់ត្រង់ត្រិបផ្កា　　ត្រេចវេហាសីទ្រហឹងខ្ចរ
ហិចហើរលើ　　អម្ពរដូចតន្ត្រីយ៏ស្ងួរស័ព្ទសម ។
ក្រឡាផ្ទៃក្រោមក្រៅ　　និរអ្នកទៅទីទូរគម
កំពស់សិលាធំ　　កំពូលភ្នំសល់សែនឆ្ងាយ ។
ព្រឹក្សព្រៃឯក្រោមក្រាស់　　ណែនណាន់ណាស់ទីទូលាយ
លុះលេចដល់វែងឆ្ងាយ　　រមើលលន្លៀកលន្លឹមលន់ ។
មើលមានត្រែងរដេច　　មានផ្កាលេចសពាសពន់
ព្រះពាយពត់ទន់ភ្លន់　　មុខគួរគន់ត្រេកត្រអាល ។
មើលស្មៅស្មោងក្រែលក្រាស់ ដុះឆ្លូកឆ្លាស់ពេញផ្ទៃវាល
ត្រែងត្រាវសោតដុះដាល　　ដាសដោយដងនាទីទៅ ។
អ្នកព្រៃដើរដុតដាល　　ត្រាញ់ត្រែងវាលសុះសព្វស្មៅ
ភ្លើងព្រៃឆេះឆាបទៅ　　ដុំប្រឆេះហើរហួសឆ្ងាយ ។
វាលវែងសន្លឹមក្រែ　　ភ្លើងភ្លឺព្រៃឆេះអាយនាយ
ប្រឆេះហើរព្រោងព្រាយ　　អណ្តែតដោយវាតាដាន ។
របាស់របែងព្រឹក្ស　　លាស់សន្ធឹកបែកយោនយាន
បុប្ផផ្លោមាន　　ដោយរដូវខែលំហើយ ។
ស្រណោះសែងសូរីយ៏　　អស់រស្មីខ្យល់រំភើយ
រំភាយផាត់រហើយ　　បក់អំពីទិសបូពិបរ ។

ស្រណោះមួយកាលគ្រា ចូលសន្និយាអាប់អម្ពរ
ព្រះច័ន្ទតារាករ រះកណ្តាលវេហាសីហើយ ។
ព្រោងព្រើសព្រះច័ន្ទ្រា វាយវាតាវឿយរំភើយ
រាត្រីស្រងាត់ជើយ ផ្សព្វត្រសៀកត្រសាក់សាយ ។
ពពកសាត់ស្រឡះ មេឃយល់ជ្រះតារារាយ
ផុំក្លិនសុរភីកាយ សព្វសុគន្ធគន្ធាធរ ។
ស្រណោះគន្ធរស ផ្សព្វក្លិនអស់ស្បង្កជករ
រាយរៀបរោយកេសរ ក្លិនរំភើយរាត្រីស្ងាត់ ។
សត្វខ្លះហើរហួសទៅ ខ្លះស្នៀងនៅហើរឆ្វៀងឆ្វាត់
ខ្លះរេរករង្គាត់ ដោយចំណីចំណាងភាន ។
ត្រសាក់សម្លេងសត្វ យំយប់ស្ងាត់ឮសព្វឋាន
ស្រណោះស័ព្ទសត្វស៊ាន លន្ទោចលើព្រឹក្សាធំ ។
ស្រណោះអាធ្រាត្រស្ងាត់ សឹងស័ព្ទសត្វទីទូរគម
ស្រៀវស្រែកត្រសាក់សម ដូចតន្ត្រីសុខស្ងួគាំ ។
ឮល្វេងអាកាសកង ស័ព្ទរំពងព្រៃព្រឹក្សា
ត្រសាក់ក្នុងសន្និយា ផ្សព្វត្រសៀកត្រសាក់សាយ ។
គន់គួរស្រណោះណាំ យើងយាត្រាតំបន់ឆ្ងាយ
ស្រើបស្រួលសាន្តសប្បាយ ដោយតំបន់អនាថា ។
ស្រណោះនាដំណើរ វែងវែងដើរដោយព្រឹក្សា

ដើរគោកដើរគង្គា សព្វអន្លើសឹងសប្បាយ ។
ស្រណោះល្បែងព្រឹក្សព្រៃ ព្រឹកវិស័យលេងលោះលាយ
រំហើយក្រសាលសាយ សោមនស្សាសុខសាន្តសស់ ។
ស្រណោះនាយើងនៅ បងនឹងចៅរែងតែងយល់
ស្រណោះដើរដោយកល យើងទាំងពីរសាន្តសាទរ ។
ស្រណោះនៅនែបនិត្យ ត្រេកត្រូវចិត្តស្នើស្នោះសរ
ថិតឋានពនេចរ កបុហប្ញទ័យសោតស្នេហ៍ស្ពាល ។"

- សរុបសេចក្តីទៅ ការរៀបរាប់ធម្មជាតិទេសភាពតាមឧបមានវិធី និងបែបតថភាពទៅតាមកាលសម័យ តាមរដូវនេះ ផ្តល់នូវសារាណីយារម្មណ៍ ដែលពោរពេញដោយក្តីស្រណោះ អាលោះអាល័យ និងទឹកចិត្តជាប់ជំពាក់ស្នេហាយ៉ាងរំភើប ។ តាមរយៈពាក្យពេចន៍តំអូញយ៉ាងអាណោចអធ័ម លន្លង់លន្លោចនេះហើយ ដែលយើងយល់នូវហឫទ័យរបស់កវីរាជ កំពុងស្លុងអារម្មណ៍ទៅលើទេវី ជាគូកំណាន់ចាស់ ដូច្នេះហើយ ទើបកម្លាំងប្រតិព័ទ្ធធ្វើឱ្យព្រះរាជសម្ភារ ដែលជាក្សត្រ ជាបណ្ឌិត អ្នកចេះដឹងច្បាប់លោក ច្បាប់ធមិ ភ្លេចភ្លាំងកាតព្វកិច្ចរបស់ខ្លួនបណ្តោយឱ្យលង់ក្នុងអំពើអបាយខាងស្នេហា រហូតដល់បានទទួលទារុណកម្មយ៉ាងសាហាវអំពីស្តេចមា និងបក្សព័ន្ធបរទេសដ៏កំណាច ។

## ៦- កំណាព្យ "កន្លង់មាសចង្កូលថ្ងៃ"

- កំណាព្យមួយផ្នែកទៀតនេះ ក៏ថិតនៅក្នុងព្រះរាជសារដែល

ព្រះរាជសម្ភារ ចែងចារផ្ញើទៅបណ្ដូលកល្យាណរបស់ទ្រង់ដែរ ។ គឺជាការប្រៀបធៀបរូបទ្រង់ទៅនឹងកន្លង់ ដែលជាបាណកសត្វចូលចិត្តនូវគន្ធរសនៃបុប្ផនានា ។ ទោះបីថិតនៅក្នុងអារាមដ្ឋានណាក៏ដោយ ឬមានម្ចាស់ការពារ ឬជាកម្មសិទ្ធិរបស់ជនបែបណាក្ដី បុប្ផជាចំណីគាប់ប្រសើររបស់កន្លង់ ។ ដូច្នេះភូមរីមិននឿយណាយ ឬបំភ្លេចចោលបានឡើយ នូវបុប្ផដែលខ្លួនធ្លាប់ស្គាល់ ធ្លាប់ត្រឹប ធ្លាប់ក្រេបរសជាតិ ។ កំណាព្យនោះមានសេចក្ដីថា ÷

## បទភុជង្គលីលា(១)

"កន្លង់មាសមង្គលថ្លៃ ឆ្វៀលឆ្វាត់វិលវៃ ទ្រហឹងខ្ចាយខ្ចរ ។
កន្លង់ត្រេចត្រង់កេសរ បងត្រេចចេរចរ ត្រង់ឋានប្អូនវ័ត្ថនី ។
កន្លង់មាសមង្គលក្ដាត់ ហិចហើរច្រវាត់ គ្រប់ដងសព្វសា ។
កន្លង់ត្រេចត្រង់បុប្ផ បងត្រេចលីលា ដល់ឋានប្អូនស្រី ។
កន្លង់មាសមង្គលថ្លៃ ច្រវាត់ឯព្វ វេហាសនភី ។
កន្លង់ត្រេចត្រង់រកភ្ញី បងត្រេចរកស្រី ស្រីមាសបវរ ។
កន្លង់មាសមង្គលចរ ទ្រហឹងអម្ពរ ឆ្វៀលឆ្វាត់វេហាស៍ ។
កន្លង់ត្រេចត្រង់បុស្បា បងត្រេចយាត្រា ដូចដល់ឋានពៅ ។
កន្លង់មាសមង្គលទៅ ស្ទោះឆ្ពោះសំដៅ ឆ្វៀលឆ្វាត់នភី ។
កន្លង់ត្រេចត្រង់រកភ្ញី បងត្រេចរកពី មានមាសស្នេហ៍ស្និទ្ធ ។

(១) ស្រង់ពីកម្ពុជសុរិយាលេខ ៨ ឆ្នាំ១៩៣៨ ទំព័រលេខ ១១១ តទៅ ។

កន្លង់មាសមង្គលវ័តនី ហើរហែឆ្វៀលឆ្វាត់ ត្រហឹងសូរសា ។
កន្លង់ត្រេចត្រង់ក្លិនផ្កា បងត្រេចត្រង់នា វិវ័តនីសង្សារ ។
កន្លង់មាសប្រាំប្រការ សសែតខ្មៅច្រាល លឿងឡែមរស្មី ។
កន្លង់ត្រេចត្រង់ឫស្សី ដូចបងនិងស្រី រួមរសស្នេហា" ។

## ៧- កំណាព្យ ព្រលឹងមាសអើយ

- កំណាព្យមួយទៀតនេះ ក៏បង្កើតនូវមនោរូបារម្មណ៍ ដែលព្រះកវីរាជ ផ្តោតចិត្តគំនិតទាំងស្រុងទៅលើអតីតគូសង្សារ ដែលព្រះអង្គទើបនឹងបានជួបវិញ ។ ក៏ប៉ុន្តែការពើបពះក្នុងខណៈនេះ ធ្វើឱ្យវិតក្កណែនចុកដើមទ្រូងព្រួយបារម្ភ គិតសញ្ជែកបែកគំនិត ភិតភ័យផង អរផង ព្រោះវិបត្តិខាងកាយនិងចិត្តម្តងនេះ ប៉ះពានលើចម្រូងចម្រាសឧបសគ្គធំណាស់ ។ យ៉ាងនេះហើយ ទើបអារម្មណ៍និងគំនួចចិត្តមេត្រីស្នេហាបុករុកផ្ញើមប្រមាត់បេះដូង ព្រះរាជាជាយុវបណ្ឌិតឱ្យធ្លាយចេញជាស្នាព្រះហស្ត ថ្លែងទុក្ខផ្សំប្រមុំនឹងអនុស្សាវរីយ៍ រៀបរាប់ទេសភាពធម្មជាតិ ឱ្យឃើញថាវត្ថុធាតុទាំងនេះ ហើយដែលជួយឧបត្ថម្ភបំពេញស្មារតី ការនឹករំពៃឱ្យស្រាកស្រាន្ត កុំឱ្យកើតវិវេគគ្រាំគ្រាបេះដូងខ្លាំងពេក ។ ផលដែលកើតមកអំពីការស្រឡាញ់ពេញចិត្ត អំពីការឃ្លាតអំពីការព្រាត់ប្រាស់និរាសចាកគ្នា មានសភាពវែងអន្លាយយ៉ាងណា ក៏ធម្មជាតិនានាដែលនៅឃ្លាតគ្នារាយប៉ាយក្នុងលោកិយ រមែងមានបច្ច័យទាក់ទិនគ្នា បង្កើតជាផលដ៏វែងអន្លាយ ជូនក្សេមក្សាន្តជាសុខសប្បាយ

រីករាយ ជូនជាទុក្ខស្រងូតស្រងាត់ លន្លង់លន្លោចយ៉ាងនោះដែរ ។ ត ពីនេះទៅ យើងឃើញអត្ថបទមានសម្រស់ដូចនេះថា ÷

## បទកាកគតិ

ព្រលឹងមាសអើយ[(១)] ថ្ងៃថើសព្រៃហើយ ទន្ទាបសុរិយា
ស្រណោះសព្វសត្វ ឆ្មៀលឆ្វាត់វេហាស៍ ចុះចាប់ព្រឹក្សា
សសិតស្លាបយំ ។

ព្រលឹងមាសអើយ ស្តាប់ស័ព្ទសត្វឆ្លើយ ទៅមកសួរសម
ខ្លះហើរផ្លេកផ្លោះ ខ្លះទ្រោះទ្រៀវយំ សំកាំងស្លាបទំ
ទន្ទឹមគូវា ។

ព្រលឹងមាសអើយ អស្តង្គតហើយ បាំងបាត់សុរិយា
បងចាំប្អូនស្រី ប្រិមប្រិយ៍សោភា វែងរំលេចផ្កា
កាល់កែមកេសី ។

ព្រលឹងមាសអើយ បងរកអស់ហើយ នៅនាលោកីយ៍
មានតែប្អូនតន់ លើសលន់អស់ស្រី រុងរឿងរស្មី
ប្រសើរថ្លៃថ្លា ។

ព្រលឹងមាសអើយ អស្តង្គតហើយ ជួបចូលសន្ធិយា
ស្រណោះព្រះពាយ ផ្សប់ផ្សាយវេហាស៍ មេឃយង់យល់ថ្លា

---

(១) ត្រូវអានថា "មាសសើយ" កុំថា "អឺយ" មិនមែនអក្សរ "អឺយ" ទេ ។ អត្ថបទកំណាព្យនេះ ស្រង់ពីកម្ពុជសុរិយា លេខ ១២ ឆ្នាំ១៩៣៨ ។

ពពកសសាត់ ។

ព្រលឹងមាសអើយ ជួបសន្ធិយាហើយ សែងសូរ្យបាំងបាត់
ព្រោងព្រះច័ន្ទ្រា ថ្លៃថ្លាឡើងថ្វាត់ រស្មីច្រវាត់
កើតកបពណ្ណរាយ ។

ព្រលឹងមាសអើយ ព្រះចន្ទ្ររះហើយ តារារៀងរាយ
ស្រណោះស័ព្ទសត្វ ស្រងាត់ឮឆ្ងាយ សូរស័ព្ទព្រះពាយ
ត្រសាក់សន្ធិយា ។

ព្រលឹងមាសអើយ ដល់រាត្រីហើយ គាប់ព្រះច័ន្ទ្រា
ប្រទក្សិណជុំ ភ្នំសុមេរា ព្រោងព្រាយវេហាស៍
ចែងចាំងច្រវាត់ ។

..ព្រលឹងមាសអើយ ព្រះចន្ទ្រចែងហើយ ស្រណោះកាលគ្រា
យល់ព្រះប្អូនថ្លៃ ប្រពៃលក្ខណា គង់នៅបរិពារ
លើសលើលោកា ។

ព្រលឹងមាសអើយ គាប់រាត្រីហើយ មានព្រះចន្ទ្រា
ពាលពេញបូណ៌មី រស្មីថ្លៃថ្លា កណ្តាលតារា
ឯកឯអម្ពរ ។

ព្រលឹងមាសអើយ ភូមិភពអាយហើយ មានតែប្អូនវរ-
មិត្រមាសកល្យាណ សាច់សាន្តសាទរ ជាឯកបវរ
មណ្ឌលទីអាយ ។

ព្រលឹងមាសអើយ ចូលអធ្រាត្រហើយ ស្រណោះព្រះពាយ
ផាត់ផើយរំភើយ លំហើយសព្វសាយ ផ្ញុំសុរភីភាយ
នារាត្រីកាល ។

ព្រលឹងមាសអើយ គាប់ផ្ញើរណោះហើយ រៀមរែងស្នេហ៍ស្នាល
សំណេះនឹងចៅ ស្ងួនពៅត្រកាល សេពសមសងសារ
សាន្តសោមនស្សា ។

ព្រលឹងមាសអើយ ឮស័ព្ទផ្ដរឆ្លើយ រោះរាយរកគ្នា
ហាក់ព្រះប្អូនរ័តន៍ នែបនិត្យស្នេហា សំណេះចរចា
នឹងបងសព្វថ្ងៃ ។

ព្រលឹងមាសអើយ រៀមរែងរួមខ្នើយ នឹងព្រះប្អូនថ្លៃ
ម្ដេចឡើយមិត្រមាស ប្រែប្រាសទីទៃ មេមិនមូលមៃ
ត្រីដូចចិត្តបង ។

ព្រលឹងមាសអើយ គាប់អធ្រាត្រហើយ ឮស័ព្ទសត្វផង
ឆ្លាស់ឆ្លើយយាសយំ សូរសមរំពង ឯអាកាសកង
ត្រសាក់សន្និយា ។

ព្រលឹងមាសអើយ គាប់ផ្ញើរណោះហើយ សត្វគៀងគូវា
ម្ដេចឡើយមិត្រមាស ប្រែប្រាសឃ្លាតឃ្លា ឱ្យតែបងផ្សា
អង្គឯងអំបាយ ។

ព្រលឹងមាសអើយ ភ្នកដល់ប្អូនហើយ ធ្វេសធ្វេរាយមាយ

នឹងស័ព្ទសត្វយំ ផ្សុំស័ព្ទព្រះពាយ ត្រសៀកផ្សព្វផ្សាយ
ត្រសាក់សួរសម ។

ព្រលឹងមាសអើយ អស់អធ្រាត្រហើយ ដល់ទៅដាស់ទុំ
ភ្ញាក់ដល់ប្អូនស្ងួន ខ្ទឹមខ្លួនឧត្តម រៀមរង់សេពសម
សង្សារមាសមិត្រ ។

ព្រលឹងមាសអើយ ចូលដាស់ទុំហើយ បងមេរ៉ែងគិត
ដ្បិតមេមាសបាត់ ស្ងប់ស្ងាត់ក្នុងចិត្ត ម្ដេចឡើយមាសមិត្រ
មិនមូលមេត្រី ។

ព្រលឹងមាសអើយ ពន់ដាស់ទុំហើយ ទៀបព្រឹកឡើងខ្ទី
ស្រណោះស័ព្ទសត្វ ស្រងាត់ឈ្មោលញី ស្រណោះច្រើនទី
មាសមិត្ររ៉ែងចាំ ។

ស្រីមាសបងអើយ(១) ស្រណោះមាសអើយ រដូវដើមឆ្នាំ
អាកាសដាសដេរ មេឃមីរជញ្ជាំ មាសអើយគួរចាំ
គិម្ហៈមាសា ។

ស្រីមាសបងអើយ ដាច់ខែចែត្រហើយ ចូលវិសាខា
ស្រណោះស័ព្ទផ្គរ ខ្ទារខ្ទរនានា ព្រើសព្រៃព្រឹក្សា
លូតលាស់ខៀវខ្ចី ។

ស្រីមាសបងអើយ រដូវភ្លៀងហើយ ធ្លាក់ចុះអំពី

---

(១) ត្រូវអានថា " បងអ៊ើយ" ។

បូព៌ាអគ្នេយ៍ ទក្សិណនិរតី បស្ចិមទិសទី
ពាយព្យឧត្តរា ។
ឮសាលាសោតហោង សួរស័ព្ទរំពង ទាំងទិសអដ្ឋា
ស្រណោះស័ព្ទផ្គរ ខ្ទរខ្ទរមេឃា ម្រឹគីម្រឹគា
លោតលងជើងលេង ។
ស្រីមាសបងអើយ សាយណ្ហហើយ ស្រណោះស័ព្ទសែង
ស័ព្ទសត្វបក្សី ឈ្មោលញីក្តោចក្តែង ដូចមាសប្អូនឯង
ដង្ហោយហៅបង ។
ស្រីមាសបងអើយ សាយណ្ហហើយ សព្វសត្វត្រសង
ហើរហែទាំងគូ នែបនៅស្នេហ៍ស្នង ដូចស្រីនួនល្អង
នឹងបងនែបនិត្យ ។
ស្រីមាសបងអើយ សួរស័ព្ទផ្គរឆ្លើយ ដោយទីឋានថិត
មើលភ្នំមើលព្រៃ ឆ្ងាយក្រែងងឹត ដង្កោលជុំជិត
គួរឱ្យស្រណោះ ។
ស្រីមាសបងអើយ ស្រឡប់ទៅហើយ សត្វផងផ្អែកផ្អោះ
ទៅដោយទ្រនំ ទៀងទំទ្រៀវទ្រោះ ផ្គរឆ្លើយឡើងស្នោះ
ពីអាកាសនាយ ។
ស្រីមាសបងអើយ[១] ចូលសន្ធិយាហើយ ផ្គរលាន់ឮឆ្ងាយ

---

(១) ត្រូវសរសេរ "បងអើយ" តែត្រូវអាន "បងង៉ើយ" ។

ស្រណោះដើមឆ្នាំ គួរចាំសព្វសាយ ស្រណោះព្រះពាយ
រំភើយវាំតា ។

ស្រីមាសបងអើយ ដល់សន្ធិយាហើយ ស្រណោះច្រើនគ្រា
ស្រណោះគិរី បក្សីបក្សា ស្រណោះវេហាស៍
ពពកសាត់សល់ ។

ស្រីមាសបងអើយ ពន់ស្រឡប់ហើយ អធ្រាត្រមកដល់
ស្រណោះដើមឆ្នាំ គួរចាំដោយកល ស្រណោះធ្លាប់យល់
ស្រីមាសមិត្របង ។

ស្រីមាសបងអើយ ពេលអធ្រាត្រហើយ សូរផ្គររំពង
ស្រណោះស័ព្ទផ្គរ ខ្ទារខ្ទរឆ្លើយឆ្លង ស្រណោះដល់ហោង
ស្រីមាសមហាថ្លៃ ។

ស្រីមាសបងអើយ ចូលអធ្រាត្រហើយ ភ្លៀងឱរក្រាស់ក្រៃ
ស្រងាត់សន្ធិយា បងមហាអាល័យ ស្រណោះនៅនៃ
កំឡុងរាត្រី ។

ស្រីមាសបងអើយ ចូលអធ្រាត្រហើយ ភ្លៀងសាទៀតថ្មី
ផ្គររឹងឮលាន់ រន្ទាន់ខ្លាំងថ្មី ស្រណោះដល់ស្រី
មាសបងឃ្លាតឃ្លា ។

ស្រីមាសបងអើយ ពន់អធ្រាតហើយ ដាស់ទុំវិញណា
ស្រណោះស័ព្ទសត្វ ស្រងាត់ភាសា ភ្លៀងឱរវេហាស៍

អាប់អស់ទិនករ ១

ស្រីមាសបងអើយ ចូលអធ្រាត្រហើយ ស្រណោះស័ព្ទផ្គរ
រន្ទះម្ដងៗ សូរសងខ្ទរខ្ទរ អាកាសអម្ពរ
ភ្លៀងស្បើយផាយផាត់ ។

ស្រីមាសបងអើយ ពន់ដាស់ទុំហើយ ឮសឹងស័ព្ទសត្វ
ស្រណោះស្រីមាស ប្រែប្រាសទៅបាត់ មាសអើយបងស្ងាត់
ស្រណោះម្នាក់ឯង ។

ស្រីមាសបងអើយ ទៀបទៅព្រឹកហើយ ឮផ្គរល្វើយល្វេង
ស្រណោះបក្សី ឃ្មោលញីសង្រេង ទ្រោះទ្រៀវយំឯង
សឹងចាកទ្រនំ ។

ស្រីមាសបងអើយ ស្រណោះព្រឹកហើយ បក្សីចេញទំ
សសិតស្លាបហើរ ផ្លោះផ្លើរហើរទំ នៅសព្វទ្រនំ
ទៅសព្វទិសផង ។

ស្រីមាសបងអើយ បងគិតទៅហើយ ស្រណោះសោតហោង
ចូលជេស្ឋមាសា គង្គាចាំលង ទឹកទល់ថ្លាខ្សង
តាំឡើងមកដល់ ។

ស្រីមាសបងអើយ ដាច់ជេស្ឋទៅហើយ អាសាធសោតសល់
ទឹកឡើងសាយក្រែ ជលស័យសាយកល់ ជោរជែងមកដល់
សំណាត់ពេញពាស ។

ស្រីមាសបងអើយ ទឹកដំឡើងហើយ ត្រីមីរដេរដាស
ចូលសព្វព្រែកខ្វែក បំបែកពោរពាស ត្រីផងទាំងផ្តាស
ចូលបឹងត្រៀបត្រា ។

មាសអើយមើលព្រែក ទន្លេហូរបែក ចូលសព្វសល់សា
សំណាត់សាត់ធ្លាក់ ព័ទ្ធពាក់លើគ្នា ហូរដោយគង្គា
ចូលព្រៃពោរពេញ ។

មាសអើយកូនត្រី ចង្វាឫស្សី ហែលលេងខ្ជួលខ្ជាញ់
កំភ្លាញកំភ្លក់ ក្អែកក្អុកក្រុះក្រាញ់ ផ្ទក់ផ្ទោងសស្រាញ់
សព្វស្មៅដៃបឹង ។

មាសអើយមច្ឆា ផ្លេកផ្លោះផ្កាប់ផ្ងារ កូនផ្ទក់ច្រឡឹង
មានត្រីតូចធំ សម្ងំសម្រឹង ហែលដោយប្រែប្រឹង
កន្ទុយវាយវាត់ ។

មើលអស់ទាំងស្មៅ លិចដើមអស់ទៅ ឃើញចុងច្រើនក្តាត់
ស្រមោចឡើងទៅ ដោយស្មៅពេនព័ទ្ធ ស្រណោះស្រីរ័ត្នន៏
មេឃ្លាតពីបង ។

មើលមានត្រីតូច ប្រឡាយរអួច ត្រីធំលាយផង[១]

.................... .................... ....................

---

(១) ត្រង់នេះ ប្រាកដជាអ្នកចម្លងឱ្យបាត់ឃ្លា ។ ខ្ញុំស្តាយណាស់ព្រោះពេលនេះខ្លី ខ្ញុំមានការមមាញឹកច្រើនពេក ឆ្លៀតស្រាវជ្រាវរកបំពេញពុំទាន់ ។

រញ្ជួយដើមដល់ ។

មុខគួរស្រណោះ ដំឡើងទឹកនោះ បងមកយង់យល់

ស្រណោះបន្ទែ កង្វែកង្ហល់ ស្រណោះច្រើនសល់

ដំណើរគង្គា ។

មាសអើយផ្ទៃបឹង ព្រលិតឈរស្រឹង លាស់លូតមានផ្កា

ស្គន់ស្គុះត្រកៀត ស៊កសៀតស្លាបទា ស្លោមស្លាបច្រវ៉ា

កំពឹងពួយពាស ។

មាសអើយកញ្ចែត សារាយអណ្តែត យាបួងឆ្លូកឆ្លាស់

................ ។ 3

- លក្ខណៈទេសភាពក្តី ធម្មជាតិក្តី ដី ទឹក ភ្លើង ខ្យល់ បក្សី បក្សា មច្ឆាផងនានាក្តីដែលព្រះកវីរាជយកមកលាតត្រដាងមានសភាពស្របទៅនឹងការពិតច្រើន ទៅតាមពេលវេលា តាមកាល តាមអាកាសរដូវ ខែ ថ្ងៃ ដែលមាននៅស្រុកខ្មែរ ។ ពិសេសទៅទៀត ការរៀបរាប់បែបនេះ (រាប់ទាំងអត្ថបទមុនៗនៃលិខិតនេះផង) ចាត់ទុកស្នាដៃមួយដែលហៅថា "លិខិត" ក្នុងអក្សរសាស្ត្រ ដែលពីមុនមិញយើងស្មានថាអក្សរសិល្ប៍ខ្មែរយើង ពុំមានអត្ថបទបែបនេះឡើយ ។

បើធៀបទៅនឹងអក្សរសិល្ប៍បារាំងក្នុងជំពូកអត្ថបទបែបលិខិតនេះ (ដូចយ៉ាងលិខិតរបស់អ្នកស្រី "**សេវីញ៉េ** = Mme de Sévigné ១៦៥៦ - ១៦៩២" កំណាព្យបែបមនោសញ្ចេតនាដែរ របស់លោក

**អាល់ហ្វ្រេដ ដឺ មុស្សេ** = Alfred de Musset ១៨១០-១៨៥៧. របស់លោក **អាល់ហ្វ្រេដ ដឺ វីញី** = Alfred de Vigny ១៧៩៧-១៨៦៣ ឬបែបលិខិតរបស់លោក **អាល់ហ្វុងស៊ី ដូដេ** = Alphone Daudet ១៨៤០-១៨៩៧ ដែលល្បីល្បាញក្នុងទ្វីបអឺរ៉ុបនោះ) យើងឃើញថា ស្នាព្រះហស្តរបស់ព្រះរាជសម្ភារ បែបលិខិតខាងលើទាំងប៉ុន្មាននេះ មានរយៈកាលមុន ហើយសម្រស់មិនមែនអន់ថយជាងកំណាព្យអ្នកល្បីល្បាញទាំងនេះ ឡើយ ។)

តើលក្ខណភាពណាមួយ ក្នុងផ្នែកវប្បធម៌ និងអក្សរសាស្ត្របែបបុរាណសម័យ ដែលធ្វើឱ្យគិតថា "ខ្មែរគ្មានអ្វីរៀន គ្មានស្នាដៃអ្វីល្អ... នោះ" ?

# ស្នាព្រះហស្តព្រះរាជសម្ភារ

## ៨-ច្បាប់ក្រម(១)

ច្បាប់នេះ មានអ្នកសិក្សារិះគន់អក្សរសាស្ត្រច្រើនរូបមកហើយ បានធ្វើអត្ថាធិប្បាយផ្សេងៗគ្នា ខ្លះឱ្យតម្លៃថាល្អ ខ្លះបង្អាប់ថាពុំប្រសើរ

(១) តាមច្បាប់បោះពុម្ពផ្សាយលើកទី ២ អំពីក្រុមពុទ្ធសាសនបណ្ឌិត្យក្នុង"ច្បាប់ផ្សេងៗ ទំព័រទី ១ ដល់ទី ៤ ពាក្យពេចន៍ សំនួនវោហារ និងគំនិតទូន្មាន ធៀបនឹងច្បាប់រាជនីតិត្រីនេត្រ មិនសូវខុសគ្នាឡើយ ។

ព្រោះជាច្បាប់ដែលពួកអភិជនសរសេរ ដើម្បីញុំាងមនុស្សឱ្យញ៉ម ឱ្យឱនលំទោន ឱ្យខ្លាច ឱ្យញ៉ាក ឱ្យជាមនុស្សកំសាក ។ល។

ក្នុងការលើកយកច្បាប់នេះមកបញ្ជាក់ ខ្ញុំជៀសវាងពុំធ្វើដូច្នេះទេ ខ្ញុំគ្រាន់តែសិក្សាអំពីលក្ខណៈពិសេសនៃការអប់រំ និងគោលបំណងខ្លះៗ នៃស្នាដៃនេះ ដូចតទៅ ÷

ច្បាប់ក្រម សំដៅទៅរកការអប់រំកុលបុត្រ-ធីតា ដូចជាគោលបំណងរបស់ច្បាប់ផ្សេងៗ អំពីបុរាណខ្មែរ ឬពាក្យទូន្មានប្រៀនប្រដៅឯទៀតៗ ដែរ ។ ពិសេស ជាការអប់រំកូនចៅដែលចូលទៅបួសរៀនផ្ញើខ្លួននឹងវត្តអារាម ព្រះភិក្ខុសង្ឃដែលទុកជាអ្នកចេះដឹងអំពីសម័យបុរាណកាល ដែលពុំទាន់មានសាលាធំតូច សម្បូរដូចសព្វថ្ងៃនេះនៅឡើយ ។ ហេតុដូច្នោះ ទើបសេចក្ដីផ្ដើមច្បាប់នេះថា ÷

"នេះគឺច្បាប់ក្រម ប្រសើរឧត្តម ទូន្មានអ្នកផង
ប្រើឱនលំទោន កុំបីមានឆ្គង ប្រាជ្ញាបុណ្យផង
កើតដោយប្រណិប័តន៍ ។
នរូអ្នកណា ទោះយកអាត្មា ចូលសាសន៍ពុទ្ធវ័ត្ត
ចូរធ្វើឱ្យត្រង់ ដោយនូវបន្ទាត់ ហៅស្វែងសម្បត្តិ
យកផ្លូវនិព្វាន" ។

ដូច្នេះ គឺជាការទូន្មានកុលបុត្រអ្នកចូលបួសរៀន អ្នកផ្ញើរូបរាងកាយផ្ទុកផ្ដាក់ខ្លួននឹងព្រះសង្ឃ នឹងវត្ត នឹងពុទ្ធសាសនា ។ បើយ៉ាង

នេះសិស្សត្រូវប្រណិប័តន៍ គោរពលំទោន ខ្លាច ស្តាប់គ្រូ ទើបចេះ ទើបមានបញ្ញា ។ ល ។... បើនឹងយកទៅវែកញែកដល់បច្ច័យទាក់ទងគ្នាទូទៅ ក្នុងរាជការធំតូចក្តី បើទោះបីប្រណិប័តន៍ឬប្រតិបត្តិ ក៏ស្រេចតែនៅលើលក្ខណៈសម្បត្តិ សមត្ថភាព សាច់ការឧស្សាហ៍ឬខ្ជិល យកចិត្តទុកដាក់ គុណសម្បត្តិល្អ អាក្រក់ សច្ចៈ យុត្តិធម៌ ឬអសច្ចៈ ទុច្ចរិត អយុត្តិធម៌ របស់បុគ្គលជាអ្នកទាក់ទងគ្នាតែប៉ុណ្ណោះ ។ គ្មានបញ្ហាអ្វីថាជឿនលឿនឬប្រតិកិរិយាក្នុងពាក្យបន្តិចត្រង់ "ប្រណិប័តន៍" ឬ "ប្រ-តិបត្តិ" នេះឡើយ ។ ស្រេចហើយតែឧត្តមគតិ ការពន្យល់បកស្រាយរបស់អ្នកសិក្សា ។ កុំលេងបដិសេធកេតនភ័ណ្ឌចាស់ ជាកេរ្តិ៍អាករថាឥតប្រយោជន៍នោះ ។ ទោះបីអាចម៍ ក៏គង់មានប្រយោជន៍ដែរ, ស្មុយមែនពិត គេខ្ពើមមែនពិត, ប៉ុន្តែខ្វះអាចម៍មិនឆ្ងាញ់ ព្រោះអាចម៍នាំឱ្យបន្លែដុះល្អ មានគុណភាពស្រស់ស្រួយឆ្ងាញ់ ។ បើពុំមានអាក្រក់ រកល្អពុំឃើញ ។ ដូច្នេះសេចក្តីអាក្រក់ល្អនៃដំបូន្មាន ស្រេចលើអ្នកសិក្សាឱ្យតម្លៃទេ ថាជាការទូន្មានមានប្រយោជន៍ ឬថាជាការឃោសនាមនោគមវិជ្ជា ឬថាអ្នកនិពន្ធ ជាអ្នកសុទិដ្ឋិនិយមពេក ឬជាអ្នកទុទិដ្ឋិនិយមពេក ។ "**ចោលបុរាណវត្ថុ គិតតែត្រង់វត្ថុសម័យថ្មី មានវិស័យដូចជាផ្ទះគ្មានគ្រឹះ**" ដើម្បីគិតច្នៃសម័យថ្មីឱ្យប្រសើរមាំ ត្រូវពិចារណារៀនមើលឱ្យច្បាស់ ពិនិត្យឱ្យជ្រៅនូវសម័យចាស់ ។ **ចោលចាស់គិតតែថ្មី បដិសេធគំនិតដូនតា គិតតែតាមគំនិតក្មេងឆៅៗ ដូចតាវៅស្រែក**

យំគ្មានដឹងទិស គ្មានគិតជាគេចូលចិត្ត ឬពុំចូលចិត្ត ពិតតែស្រែកថា តាវ៉ៅៗ ហៅតែខ្លួនឯង សំដែងតែសំដីឯងម្នាក់ឯង។ នឹងយល់សម្រេចគំនិតថ្មី ទាល់តែយល់ដឹងវិវត្តន៍នៃគំនិតចាស់ ។ បើនឹងប្រៀបធៀបអត្ថបទក្នុងអក្សរសិល្ប៍សម័យថ្មី ទៅនឹងអត្ថបទមុនៗ ក្នុងសម័យដើម តើដឹងសម្រស់អត្ថន័យ អត្ថរូប អត្ថរស នៃស្នាដៃបច្ចុប្បន្នដល់កម្រិតណាមួយឱ្យច្បាស់ហើយឬនៅ?

- តទៅទៀត យើងឃើញច្បាប់ក្រមលាតត្រដាងការអប់រំកូនចៅខាងផ្លូវកាយ វាចាចិត្ត ឱ្យមានបែបបទជាកុលបុត្រ កុលធីតា មានសីលធម៌ សុជីវធម៌ ការឧស្សាហ៍ឱហាតសង្វាតសូត្ររៀន ស្គាល់ល្អអាក្រក់-ធំតូច-ខ្ពស់ទាប ។ ច្បាប់ក្រមអប់រំអ្នកគ្រប់គ្រង អ្នកដឹកនាំគ្រួសារ ក្នុងសង្គមសង្ឃ ក្នុងសង្គមជាតិ ឱ្យដឹងខុសត្រូវ ឱ្យដឹងច្បាប់ទម្លាប់ ទៅជាពលរដ្ឋប្រសើរ ។ ពិតមែនហើយថា កុំឱ្យគោរពដល់ទៅខ្លាចញ៉ូវបាត់ស្មារតី បាក់បបខ្លបខ្លាច ប្រែជាអកម្មស្លឹកទ្រមក់នោះ ។ តែសម័យថ្មី មិនត្រូវអប់រំឱ្យទៅជាក្លាហានអង់អាច ដល់ថ្នាក់ព្រហើនកោងកាច លែងខ្លាចអំណាច លែងស្គាល់ម៉ែឪ គ្រូបាអាចារ្យ អ្នកគ្រប់គ្រងទទួលខុសត្រូវក្នុងសង្គមតូចធំនោះទេ។ ព្រោះថាបើដូច្នោះ អនាធិបតេយ្យក៏នឹងកើតមាន ហើយសិទ្ធិសេរីភាពរបស់បុគ្គល ក៏នឹងប៉ះទង្គិចពានពារលើគ្នា កើតជាជម្លោះចម្បាំង កាប់សម្លាប់គ្នាជាប្រាកដហើយមនុស្សនឹងក្លាយទៅជាយក្សឬជាតិរច្ឆាន ។ សេចក្តីពណ៌នាមក

ប៉ុណ្ណេះ គ្រាន់តែចង់បង្ហាញថា ដំបូន្មានប្រៀនប្រដៅ ជាការចាំបាច់របស់មនុស្ស ពីស្រុកមួយទៅស្រុកមួយ ពីជំនាន់មួយទៅជំនាន់មួយ ហើយស្របទៅតាមតម្លៃវ័យ តម្លៃមុខងារទទួលខុសត្រូវ របស់បុគ្គលម្នាក់ៗ ព្រមទាំងស្របទៅតាមទំនៀមទម្លាប់ ប្រពៃណីរបស់ជាតិស្របតាមរបបគ្រប់គ្រងរបស់ប្រទេសនីមួយៗ តែប៉ុណ្ណោះ ។ សុំកុំច្រឡំថា យើងអាចយកទំនៀមទម្លាប់ជនជាតិមួយ ទ្វីបមួយ សាសន៍មួយ ទៅអនុវត្តចំពោះជនជាតិផ្សេង សាសន៍មួយផ្សេង បានដោយស្រួលនោះឡើយ។ បើធ្វើដូច្នេះបាន ប្រហែលមានសាសន៍តែមួយ លទ្ធិតែមួយ ជាឯកភាពក្នុងសកលលោកទៅហើយ! តើមានអាទិទេពណាអាចទាញទឹកចិត្តមនុស្សទាំងសាកល ឱ្យលុះក្នុងទ្រឹស្ដីនិងធម៌របស់ខ្លួនបានហើយឬនៅ ?

- លក្ខណៈមួយទៀត ច្បាប់ក្រមរាប់បានថាជាច្បាប់អប់រំបែបគរុកោសល្យ និងចិត្តសាស្ត្រថែមទៀត ដូចជាថា ÷

"សង្វាតសរសេរ អស់អញកុំខ្ជិល ទើបបានជាឆាប់
សង្វាតសូត្ររៀន ដោយគ្រូប្រញ៉ប្ដ កុំធ្វើលេលាប់
ដោយចិត្តមាក់ងាយ ។
ហៃអស់សាមណេរ ម្ដាយមកបង្ហើរ អ្នកជាបាធ្យាយនី
សង្វាតសូត្ររៀន ដូចលោកទាំងឡាយ កុំធ្វើពាយងាយ
ដូចនៅគ្រហស្ថ ។

កុំធ្វើវាយមាយ នឹងគ្រូបាធ្យាយនី ទុកស្មើអម្ចាស់
សង្វាតសរសេរ សូត្ររៀនឱ្យណាស់ ប្រាជ្ញាយល់ច្បាស់
នាំញាតិទាំងឡាយ ។

"សាមណេរណាៗ ទោះមានប្រាជ្ញា នឹងចង់រៀនត្រាប់
ឱ្យយកត្រចៀក នោះឱនចូលស្ដាប់ ធ្វើដោយក្រមច្បាប់
នៃគ្រូបាធ្យាយនី" ។

"វីនឹងចេះឯង ដូចអ្នកវង្វេង កណ្ដាលអធ្វា
ពុំនោះដូចខ្វាក់ តែម្នាក់អាត្មា ចរចេញយាត្រា
ឥតអ្នកដឹកដៃ" ។

កាព្យទាំងនេះ គឺជាការទូន្មានសិស្សានុសិស្ស (ពិសេសសាម-ណេរ) ពីព្រោះសម័យដើមមានតែការចូលបួសក្នុងវត្តអារាមទេ ទើបបានរៀនសូត្រ។ បានសេចក្ដីថា វត្តជាសាលាពហុវិជ្ជាខាងអក្សរសាស្ត្រ សិល្បៈ បច្ចេកទេស នីតិសាស្ត្រ សង្គមវិជ្ជា នយោបាយ។ល។ ហើយព្រះសង្ឃជាគ្រូតាំងពីជាន់ទាប ដល់ថ្នាក់សាស្ត្រាចារ្យ អាចារ្យទិសាបា-មោក្ខ ។ នេះហើយដែលយើងឃើញថា គំនិតអប់រំ បែបគរុកោសល្យវិជ្ជា ចិត្តវិជ្ជារបស់ខ្មែរ មានហើយតាំងពីសតវត្សទី១៧ នៃគ.សម្លេះ។ ទោះបីឃើញថាការអប់រំឱ្យចេះខ្លាចគ្រូ ស្ដាប់ឱវាទគ្រូ ទុកគ្រូជាធំនេះក៏ដោយ ក៏ការប្រដៅបែបនេះ ពុំមែនប្លែកអំពីគរុកោសល្យសាស្ត្រសម័យថ្មីដែរ ។ ពិតមែនតែគេទុកគ្រូបង្រៀនជាអ្នកដឹកនាំផ្លូវ មិនឱ្យ

វាយដំច្រំធាក់សិស្សក៏ដោយ ក៏គង់តែពុំមែនបណ្តោយសិស្ស ឱ្យមានសេរីភាពទៅជាកោងព្រហើន ពុំខ្លាច ពុំស្តាប់បង្គាប់គ្រូដែរ ។ តាមធម្មតា សិស្សណាបើពុំខ្លាចគ្រូ ពុំគោរព ជឿជាក់នូវសមត្ថភាពគ្រូ សិស្សនោះរៀនពុំចេះ ហើយបើរៀនខ្លួនឯងវិញ ចេះដែរតែចេះខាងដើរផ្លូវឆ្វេងម្នាក់ឯង ទុកដូចជាខ្វាក់ ។

- លក្ខណៈចុងក្រោយ គឺជាការអប់រំបុត្រធីតាឱ្យគោរពមាតាបិតានិងគ្រូអាចារ្យ ដែលជាអ្នកបង្កើតចិញ្ចឹមបីបាច់ ជាអ្នកឱ្យចំណេះវិជ្ជា ។ ការទូន្មានបែបនេះ ប្លែកអំពីទំនៀមទម្លាប់អឺរ៉ុប ហើយស្របទៅតាមចិត្តថ្លើមនិងជំនឿរបស់ជនជាតិអាស៊ី ពិសេសគឺខ្មែរជាអ្នកមានកតញ្ញូតាធម៌ ស្គាល់បុណ្យ ស្គាល់បាប ជឿក្នុងព្រះត្រៃរ័ត្ន ។ សេចក្តីនេះមានដូច្នេះ ÷

"ព្រះជនកព្រះជននី បើនឹងស្រដី ប្រសើរពេកពន់
ថាភ្នំព្រះសុមេរុ នោះហោងមហាធ្ងន់ ថាបើនឹងគណន៍
ពុំអាចកន្លង ។
រីគ្រូបាធ្យាយន៍ ប្រដូចនូវម្តាយ អាពុកឯងហោង
អាចឱ្យក្តីច្បាប់ ប្រដៅធម៌ផង ដោយនូវគន្លង
ព្រះពុទ្ធទាំងឡាយ" ។

បើយកលក្ខណៈនៃការទូន្មានបែបនេះថាជាប្រតិកិរិយា ពេលនោះសតិសម្បជញ្ញៈរបស់មនុស្ស នឹងធ្លាក់អន់ជាងសត្វតិរច្ឆាន មានផ្តែ

ឆ្នា ឬសេះជាដើម ទៅទៀត ។

សរុបសេចក្តីទៅថា ច្បាប់ក្រមលាតត្រដាងនូវចិត្តថ្លើមប្រពៃណី ជំនឿ ទំនៀមទម្លាប់និងជីវភាព បច្ច័យទាក់ទងរបស់ប្រជាពលរដ្ឋខ្មែរក្នុងសង្គមតូច រហូតដល់សង្គមជាតិជាបរិយោសាន ។

## ៩- ច្បាប់ត្រីនេតិ

- ត្រីនេតិ ជាច្បាប់ប្រកបដោយអង្គបីនៃការទូន្មាន ពោលគឺការទូន្មានជាបី៧បទ ។ កវីរាជសំដៅការអប់រំទៅលើការរស់ ការទាក់ទងជាបច្ច័យរវាងគ្នា នៃនរជនដែលជារាជាមាត្យ ជាមន្ត្រី ជាសេនា ជាកវីបណ្ឌិត ជាអ្នករាជការបម្រើព្រះមហាក្សត្រ ជាប្រជារាស្ត្រ និងប្រទេសជាតិ មានសេចក្តីដូចតទៅ ÷

"នរូអ្នកណា នឹងចូលទៅជា វររាជអាមាត្យ
សេនាមន្ត្រី កវីជាអាទិ៍ រៀនច្បាប់ជាខ្នាត
តែងទុករៀងទៅ ។ ...

ដ្បិតមុខមន្ត្រី សេនាបតី ពុំដោយគន្លង
លោភោបង់បាន បំពានរាស្ត្រផង រាស្ត្ររឹងក្តៅហោង
អង្គឥតអាស្រ័យ ។

រាស្ត្រដូចមច្ឆា មន្ត្រីសេនា ដូចគង្គានៃ
បើប្រែជាក្តៅ ក្រៃក្រៅវិស័យ រាស្ត្ររឹងកើតភ័យ
អង្គឥតពំនាក់ ។

មន្ត្រីយោធា បីដូចព្យគ្ឃា និងពស់ពញ្លាក់
រីអស់រាស្ត្រផង ចរចូលពឹងពាក់ ក្សិណប្រែជាយក្ស
យល់ឥតករុណា" ។

- ឯលក្ខណៈបីៗ នៃច្បាប់ទូន្មាននេះ មានសេចក្ដីសង្ខេបដូចតទៅ ÷

ក/- កូនកាចកំណាច វិនាសសន្តាន (ហៅកុបុត្តំ);

- នៅភូមិអាក្រក់ កើតមានព្យាធិ ពុំប្រពៃ (ហៅកុភូមំ)

- នៅផ្ទះអាក្រក់ កើតហិនហោច អាប់ឥតមង្គល (ហៅកុគេហំ)

ខ/- មន្ត្រីល្អមានប្រាជ្ញាដឹងអស់អធ្យាស្រ័យ ធ្វើឱ្យក្សេមក្សាន្តនគររាស្ត្រមណ្ឌល (ហៅសុមន្ត្រី)

- កូនមានគំនិតល្អ នាំចម្រើនបងប្អូនសាច់សន្តាន (ហៅសុបុត្តំ).

- ភូមិស្ថាន ផ្ទះសម្បែងល្អ នាំចម្រើនធនធាន ចម្រើនប្រាជ្ញាដល់អ្នករស់នៅ (ហៅសុភូមំ និងសុគេហំ) ។

គ/- លក្ខណៈអសារឥតការកើតមកអំពី ÷

- មានទ្រព្យ ពុំធ្វើបុណ្យសងគុណគេ.

- ពុំកាន់សីល គ្មានពាក្យទៀងត្រង់ ពុំចង់បានបុណ្យ ពុំប្រណិប័តន៍សង្ឃ ពុំឧស្សាហ៍.

- ពុំស្តាប់ធមិ ពុំកាន់ក្រមក្រិត្យច្បាប់ ពុំធ្វើបរិសុទ្ធ ។

ឃ/- លក្ខណៈផ្គង់បីយ៉ាងគឺ ÷

- ស្នេហាកុំភ្លេចសំណោះសំណាលសាកសួរស្នេហ៍ស្នង

- ភរិយាដោយការឱ្យរក្សានូវទ្រព្យធន ផ្ទះសម្បែង

-បុត្រដោយឱ្យរៀនសាស្ត្រាសិល្បច្បាប់ រិះរកភរិយាល្អឱ្យ ។

ង/- លក្ខណៈហីន បីបែបគឺ ÷

- ហីនលក្ខណ៍ ដោយការអួតអាងសរសើរតែអាត្មាឯង,

- ហីនស័ក្តិ ដោយការធ្វើខ្លួនឱ្យអប្រិយអាក្រក់ក្នុងការចេញទៅជិតឆ្ងាយ,

- ហីនសួស្តី ដោយទុកផ្ទះភូមិឋានឱ្យអប្រិយក្រខ្វក់ ។

ច/- លក្ខណៈវិនាស ៣សណ្ឋាន គឺ ÷

- បាត់ស្និទ្ធដោយពោលពាក្យខុសចិត្តគេ ឱ្យបខ្សៀវ ជេរគេធ្វើមុខអាក្រក់ និយាយភរកុហក,

- បាត់មិត្រដោយពោលពាក្យពុំពិតគ្មានទៀងត្រង់ ខ្ចីទ្រព្យគេពុំសងវិញ,

- បាត់ពន្លឺដោយពុំចេះមើល ពុំយល់កិច្ច ពុំចេះពិចារណា ។

ឆ/- លក្ខណៈវិនាស ៣យ៉ាងទៀត គឺ ÷

- បាត់ខុនណាង ដោយពុំដឹងខ្លួនចាស់និយាយឡេះឡោះ,

- បាត់ជាងជាតិដោយធ្វើការឥតខ្នាតគ្មានចប់ចុងចប់ដើម

- បាត់ប្រាជ្ញដោយនៅស្ងៀមស្ងាត់ក្នុងកាលជំនុំ ។

ជ/- លក្ខណៈមានបាន ៣ បែបគឺ ÷

- មានរសក្នុងការសេពអាហារ វាចាល្អ ភរិយាប្រពៃ,

- មានសប្បុរស ដោយមានធម៌ ឈ្លាសវៃ ចេះពិចារណាខុសត្រូវ,

- មានពន្លឺ ដោយសារបញ្ញាប្រកប ភរិយាចេះគោរពប្រតិបត្តិតាម ។

ឈ/- លក្ខណៈហិនហោច ត្រមោច និងសាធារណ៍ ÷

- ហិនហោចដោយខ្លួនខ្លៅគប់តែនឹងអ្នកប្រមឹក មានប្រពន្ធមាយា,

- ត្រមោចកណ្តោចកណ្តែង ដោយមានវិជ្ជាពុំបង្រៀនគេ គ្មានបុត្រធីតាសោះ,

- សាធារណ៍ កើតមកពីមានព្រៀងឥតការ ប្រពន្ធឫស្យាអាត្មាទុរពល ជំពាក់បំណុលជុំខ្លួន ។

ញ/- លក្ខណៈសាមាន្យ អន្តរធាន និងអាស្រូវ ÷

- សាមាន្យ ដោយសារសង់ផ្ទះជិតទីផ្សារ គប់មនុស្សពាលមោហា ប្រពន្ធជំពាក់បំណុលគេ,

- អន្តរធានដោយសារសង់ផ្ទះជិតផ្លូវ ខ្លួនឯងអប្រិយប្រពន្ធប្រមឹក,

- អាស្រូវ ដោយសារសង់ផ្ទះជិតផ្លូវថ្នល់ ម្តាយក្មេកពុំជាមាត់រឹង ប្រពន្ធគេលែងក្បាលចោល ។

ង/- លក្ខណៈបរលោក ពុំថោក និងលោកិយ ÷

- បរលោក ដោយមានគ្រូប្រកបដោយប្រាជ្ញាជួយដឹកខ្លួន, ខ្លួនពុំខ្ជិល, ចាំសីលភាវនា, ចិត្តសទ្ធាល្អប្រសើរ,

- ពុំថោក ដោយចេះរក្សាខ្លួន អង្គុយស្គាល់ខ្ពស់ទាប ភរិយាគាប់ ត្រកូលថ្លៃ,

- លោកិយ ដោយពុំយល់តែខ្លួនឯង, មានច្បាប់, ពោលពាក្យសត្យាពិរោះ សមសាទរល្អ ។

ច/- លក្ខណៈប្រាសលោក ថយថោក និងប្រាស លោកុត្តរៈ

- ប្រាសចាក កើតមកពីស្រដីថោក និយាយពុំជាមាត់រឹង ពុំប្រណិប័តន៍ចាស់ព្រឹទ្ធា,

- ថយថោក ដោយសារខ្លួនជាទុរជន,

- ប្រាសចាកលោក ដោយសារគ្មានធម៌ពុំប្រណិប័តន៍សង្ឃ ពុំកាន់សីលទាន បំបាត់ជីវិតសព្វសត្វ មានប្រពន្ធបីជាអកុសល ។

៣/សរុបសេចក្តីទៅ ច្បាប់ត្រីនេតិសង្កត់ការអប់រំទៅលើសតិស្មារតីរបស់អនុជន ឱ្យប្រព្រឹត្តទៅតាមគន្លងច្បាប់ គតិលោក និងគតិធម៌ ។ ពិសេសជាងនេះ ខ្ញុំរាជការឯណាដែលប្រកបលក្ខណៈ ចរិយាការប្រព្រឹត្តិទៅតាមបែបបទ គន្លងនៃច្បាប់នេះ នឹងពិតជាបានទៅជា

អ្នកបម្រើប្រទេសជាតិ មាតុភូមិ និងប្រជារាស្ត្របានប្រសើរ ។ ហេតុនេះហើយទើបនៅមុនការបញ្ចប់ព្រះកវីរាជទូន្នានចំពោះព្រះរាជាថា ÷

"ព្រះអង្គមហាក្សត្រិយ៍ សោយរាជសម្បត្តិ គ្រងរាជមណ្ឌល
រើសរកសេនា ឱ្យជាខុនពល ហើយនឹងដឹកល់
ស្នងព្រះនេត្រនៃ ។
.................. ក្រឡាពាសធំ មានប្រាជ្ញាវៃ
ស្គាល់គ្រប់រាជការ ។
ស្គាល់ទោសស្គាល់គុណ ស្គាល់ក្រោយស្គាល់មុន ដើមចុងកណ្តាល
ស្គាល់បាបស្គាល់បុណ្យ ស្គាល់ធ្ងន់ស្គាល់ស្រាល ស្គាល់ប្រាជ្ញស្គាល់ពាល
ស្គាល់ហ៊ានស្គាល់ខ្លាច ។
ស្គាល់តិចស្គាល់ច្រើន សង្វាតក្រវើន ស្គាល់អត់ស្គាល់ឃ្លាន
ស្គាល់វៀចស្គាល់ត្រង់ ស្គាល់ភូតស្គាល់មែន ស្គាល់ដីស្គាល់ដែន
ស្គាល់ព្រៃស្គាល់ត្រាញ់ ។
ស្គាល់គាប់ស្គាល់ខុស ស្គាល់ស្លាប់ស្គាល់រស់ ស្គាល់ឈ្នះស្គាល់ចាញ់
ស្គាល់បាញ់ស្គាល់បោះ ស្គាល់ដោះស្គាល់ដេញ ស្គាល់ចូលស្គាល់ចេញ
ស្គាល់បាត់ស្គាល់បង់ ។
ស្គាល់តឹងស្គាល់ធូរ ស្គាល់ឆាប់ស្គាល់យូរ ស្គាល់ហូលស្គាល់ខៀន
ស្គាល់ដើរស្គាល់ដេក ស្គាល់ស្រេកស្គាល់ឃ្លាន ស្គាល់បង់ស្គាល់បាន
ស្គាល់មានស្គាល់ខ្សត់ ។

បើមានកង្វល់ កលិយុគមកដល់ គេប្រាប់ប្រាកដ
បាកុំឆោតឆ្វល់ វិលវល់វន្ធត់ កុំផ្សូរឃូររត់
តម្អក់តម្អឹង ។
កុំច្រើនវង្វេង ងងោងងងេង មមឹងមមឹង
កុំច្រើនប្រទូស្ត រឹងរូសរបឹង កុំខ្ជិលរំពឹង
តែដេកនិទ្រា ។
កុំលោភចង់បាន ទ្រព្យគេបំពាន ពន្លឹកសោះសា
កុំរៀនកំណាញ់ ស្វិតស្វាញឬស្សា ពុំស្គាល់កាចជា
ពាក្យពេចន៍ទ្រគោះ ។
កុំលេងជាល្បែង រំពឹងយល់ឈ្វេង ពាក្យពុំពិរោះ
ស្រដីឱ្យដាច់ ឱ្យស្រេចឱ្យសោះ កុំធ្វើឡេះឡោះ
សសោះអន្ទង ។
កុំធ្វើហេងហាង កុំអួតកុំអាង ខុសក្តីបំណង
កុំច្រើនក្រអែស ប្របហែសលេងលង ឱ្យរៀនត្រងរង
នូវក្តីអំណត់" ។

## សេចក្តីសន្និដ្ឋាន

ការលើកយកនូវជីវប្រវត្តិ និងស្នាព្រះហស្ថរបស់ព្រះបាទស្រីធម្មរាជា ចៅព្រះរាជសម្ភារ មកបញ្ជាក់ទាំងប៉ុន្មានខាងលើនេះ សឱ្យឃើញថា ក្នុងអក្សរសិល្ប៍ខ្មែរយើង មានអ្នកនិពន្ធយ៉ាងសំខាន់ណាស់នៅក្នុងសតវត្សទី ១៧ ដែលកន្លងទៅហើយជាង ៣០០ ឆ្នាំនេះ ។ ពិតមែនតែព្រះអង្គទទួលបាបគ្រោះ សោយព្រះទិវង្គតទៅនៅក្នុងយុវវ័យយ៉ាងនេះក៏ដោយ ក៏ព្រះមហារាជអង្គនេះ ទ្រង់បានទុកព្រះកេរ្តិ៍សំរាប់ឧបត្ថម្ភ លើកដំកើងអក្សរសិល្ប៍ខ្មែរ ឱ្យគង់ពន្លឺរស្មីចិញ្ចែងរហូតមកទល់បច្ចុប្បន្ននេះដែរ ។ គួរស្តាយពន់ពេក ប្រសិនបើទ្រង់គង់ព្រះជន្មបានវែងជៀសផុតអំពីគ្រោះថ្នាក់បណ្តាលមកអំពីសកម្មភាពផ្ទាល់របស់ព្រះអង្គ និងការព្យាបាទសងសឹកដ៏ក្រខ្វក់ឥតមេត្តាករុណានិងអមនុស្សធម៌របស់ព្រះឧទ័យមា ព្រមទាំងបក្សព័ន្ធនោះ នោះប្រហែលជាយើងនឹងបានទទួលនូវព្រះអំណោយជាអនុស្សាវរីយ៍ ជាគ្រឿងបណ្តុះនូវសតិបញ្ញា ពោលគឺមានអត្ថបទសំខាន់ៗច្រើនទៅទៀតជាប្រាកដ ។

**ចប់**

CATALOGED IN ALEPH
No: 29460
Date: 27.4.2013

# រោងពុម្ព
# បណ្ណាគារ បន្ទាយស្រី




**ផ្ទះលេខ 73-75 Eo ផ្លូវប៉ាស្ទ័រ ភ្នំពេញ**

**តូបលេខ 23-24 ផ្សាររុស្ស៊ី**

**ទូរស័ព្ទលេខ : 012 923 933**

**011 860 960**